មជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី
NEW GENERATION PEDAGOGICAL RESEARCH CENTER

# ការបង្រៀនតាមវិធីសម្ដែងតួ




Stanislas Kowalski
First Edition: 2025

# មជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី

New Generation Pedagogical Research Center

សៀវភៅ៖

# មគ្គុទ្ទេសក៍គរុកោសល្យ
# ការបង្រៀនតាមវិធីសម្តែងតួ

២០២៥

**រក្សាសិទ្ធិ៖ © ការបង្រៀនតាមវិធីសម្តែងតួ ២០២៥**
**រក្សាសិទ្ធិគ្រប់យ៉ាង**

កូនសៀវភៅនេះមានចំណងជើងថា "**ការបង្រៀនតាមវិធីសម្តែងតួ**" ត្រូវបានការពារដោយច្បាប់រក្សាសិទ្ធិ។ គ្មានផ្នែកណាមួយនៃសៀវភៅនេះអាចត្រូវបានចម្លង ចែកចាយ ឬបញ្ចូលក្នុងទម្រង់ណាមួយ ឬតាមរយៈវិធីសាស្ត្រណាមួយ រួមទាំងការថតចម្លង ការថតសំឡេង ឬវិធីសាស្ត្រអេឡិចត្រូនិក ឬមេកានិកផ្សេងៗទៀត ដោយមិនមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីអ្នកនិពន្ធជាមុនសិន លើកលែងតែករណីសម្រង់សំខាន់ៗសម្រាប់អត្ថបទវិចារណកថា ឬការពិនិត្យឡើងវិញ។

រូបភាពត្រូវបានបង្កើតឡើងដោយ ChatGPT 5។

សម្រាប់សំណើសុំការអនុញ្ញាតសូមទាក់ទងមកកាន់៖
**មជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី** [NGPRC]

**រៀបរៀងដោយ៖** លោក Stanislas Kowalski

**បកប្រែជាភាសាខ្មែរ៖** លោកគ្រូ **ឆោ សៅរិទ្ធ**
អ្នកគ្រូ **ស៊ីម វណ្ណាសុខាលីលី**

**ក្រាហ្វិចឌីហ្សាញ៖** លោកគ្រូ **ជី គឹមអ៊ី**

## មាតិកា ទំព័រ


សេចក្តីផ្តើមៈការដាក់ពិន្ទុដល់ការចូលរួមរបស់សិស្ស .................... 3

បញ្ហាប្រឈមមួយចំនួនត្រូវដោះស្រាយ ........................................ 5

ការហ្វឹកហាត់វាក្យស័ព្ទនិងវេយ្យាករណ៍ ....................................... 9

គោលការណ៍ស្តង់ដាពេលអនុវត្តវិធីសម្តែងតួ ........................... 11

វិធីដោះស្រាយជាមួយនឹងភាពខ្មាសអៀន? ................................ 14

វិធីផ្តល់មតិត្រឡប់ដល់សិស្ស .................................................... 17

តើត្រូវប្រើពេលប៉ុណ្ណាសម្រាប់ការសម្តែងបែបធម្មជាតិ? .......... 19

ឧបករណ៍ៈ សេណារីយ៉ូ ............................................................. 21

កម្រិតមូលដ្ឋាន ......................................................................... 23

កម្រិតមធ្យម ............................................................................... 30

កម្រិតខ្ពស់ ................................................................................. 39

សេណារីយ៉ូផ្ទាល់របស់ខ្ញុំ ............................................................. 44

ការឆ្លុះបញ្ចាំងលើម៉ោងបង្រៀនដោយប្រើវិធីសម្តែងតួ .............. 45

## សេចក្តីផ្តើមៈការដាក់ពិន្ទុដល់ការចូលរួមរបស់សិស្ស

កាលខ្ញុំនៅជាសិស្សវិទ្យាល័យ ខ្ញុំកម្រនឹងបាននិយាយ ភាសាអង់គ្លេសក្នុងថ្នាក់រៀនភាសាអង់គ្លេសណាស់។ ប្រសិនបើខ្ញុំអាចនិយាយភាសាអង់គ្លេសនៅកន្លែងធ្វើការរបស់ខ្ញុំបានដូចសព្វថ្ងៃនេះ វាមិនមែនដោយសារតែការបណ្តុះបណ្តាលក្នុងសាលារៀននោះទេ។ ជាអកុសល ស្ថានភាពរបស់ខ្ញុំមិនមែនជារឿងចម្លែកនោះទេ។ ក្នុងមេរៀនភាសាបរទេស គ្រូបង្រៀនជាច្រើន តែមិនមែនភាគច្រើនទេ ផ្តល់ពិន្ទុដល់ការចូលរួមរបស់សិស្សរបស់ខ្លួន។ គ្រូសួរសំណួរទៅសិស្សទាំងអស់ក្នុងថ្នាក់ ហើយរំពឹងថានឹងមានអ្នកស្ម័គ្រចិត្តលើកដៃដើម្បីឆ្លើយសំណួរ។ វិធីនេះជាការអនុវត្តមិនប្រសើរ និងគ្មានការច្នៃប្រតិដ្ឋ។ អ្នកអាចសាកល្បងដើម្បីផ្ទៀងផ្ទាត់ចំពោះការលើកឡើងរបស់ខ្ញុំ ។ ទំហំថ្នាក់រៀនធម្មតាមានសិស្សចាប់ពី ២៥ ទៅ ៣០ នាក់ ឬច្រើនជាងនេះទៀត ប្រសិនបើយើងនៅក្នុងប្រទេសកំពុងអភិវឌ្ឍ។ មេរៀនធម្មតាមានរយៈពេលចន្លោះពី ៤៥ ទៅ ៥៥ នាទី អាស្រ័យលើប្រព័ន្ធរបស់សាលារៀន។ នេះមានន័យថា ជាមធ្យម សិស្សម្នាក់ៗមានឱកាសនិយាយតិចជាង ២នាទី ហើយខ្ញុំមិនបានរាប់បញ្ចូលពេលវេលាដែលគ្រូចំណាយលើការពន្យល់មេរៀន ឬលំហាត់ផ្សេងៗនោះទេ។ មិនមែនជារឿងគួរឱ្យភ្ញាក់ផ្អើលទេដែលសិស្សភាគច្រើនមិនបាននិយាយសោះនោះ។ តាមរយៈបទពិសោធរបស់ខ្ញុំក្នុងនាមជាគ្រូប្រឹក្សាគរុកោសល្យ និងការពិភាក្សាជាមួយគ្រូបង្រៀនភាសាអង់គ្លេសជាច្រើន ការពិភាក្សាក្នុងថ្នាក់ត្រូវបានធ្វើឡើងដោយសិស្សត្រឹមតែ ៤ ឬ ៥ នាក់ដែលសកម្មជាងអ្នកផ្សេង។ វាមិនសំខាន់ទេថាសិស្សថ្នាក់នោះមានទេពកោសល្យឬអត់។ អ្វីដែលសំខាន់នោះគឺការដណ្តើមពេល

វេលានិយាយក្នុងការប្រកួត (និយាយចំណុច និងមានភាពច្បាស់លាស់)។ យើងត្រូវការប្រព័ន្ធមួយដែលធ្វើឱ្យសិស្សនិយាយក្នុងពេលតែមួយ មិនមែននិយាយតាមវេនទេ។

គ្រូខ្លះសុំឱ្យសិស្សរបស់ខ្លួនទន្ទេញការសន្ទនាពីក្នុងសៀវភៅសិក្សាគោល។ ជាការពិតណាស់ ការសន្ទនាដែលបានរៀបចំទុកជាមុនទាំងនោះផ្តល់ឱ្យសិស្សនូវអនុវត្តជាក្រុមតូចៗ ដូច្នេះពួកគេមានពេលវេលានិយាយច្រើនជាងមុន ប៉ុន្តែមិនអាចផ្តល់ភាពបត់បែនគ្រប់គ្រាន់ដល់ពួកគេដើម្បីដោះស្រាយជាមួយស្ថានភាពជីវិតពិតបានទេ។
តាមពិត វិធីសម្តែងតួគឺជាលំហាត់ដ៏ពេញលេញ និងពាក់ព័ន្ធបំផុតសម្រាប់បង្រៀនជំនាញនិយាយ និងស្តាប់។ កាលអាកាសនៅក្នុងរឿងសម្តែងគឺជាគុណសម្បត្តិចម្បងនៃសកម្មភាពនេះ។ ជាមួយនឹងវិធីសម្តែងតួដ៏ល្អ គេស្នើរតែមិនត្រូវការការវាយតម្លៃជាផ្លូវការនោះទេ។ ឃ្លាឆ្លើយឆ្លងក្នុងសាច់រឿងអាចលាតត្រដាងបានក្បោះក្បាយ ឬមិនបានក្បោះក្បាយ។ តួសម្តែងអាចយល់គ្នាទៅវិញទៅមកបាន ឬមិនបាន។ វិធីសម្តែងតួផ្តល់នូវ ខ្លឹមសារនៃគោលបំណងក្នុងមេរៀន។ ការសម្តែងតួជាការបង្កើន មោទនភាពចំពោះខ្លួនឯងនៅក្នុងដំណើរការសម្តែង។ ប្រសិនបើវាត្រូវបានធ្វើយ៉ាងត្រឹមត្រូវ សិស្សនឹងដឹងភ្លាមៗនូវស្ថានភាពជីវិតពិតដែលពួកគេអាចដោះស្រាយបានជាមួយនឹងជំនាញនិយាយបច្ចុប្បន្នរបស់ខ្លួន។

## បញ្ហាប្រឈមមួយចំនួនត្រូវដោះស្រាយ

បើទោះបីវិធីសម្ដែងតួមានសារៈប្រយោជន៍យ៉ាងណាក្ដី ក៏គេកម្រ បានប្រើប្រាស់វិធីសម្ដែងតួនេះ នៅក្នុងថ្នាក់រៀនណាស់។ មានហេតុផល មួយចំនួនចំពោះរឿងទាំងអស់នេះ។ យើងត្រូវយល់ពីឧបសគ្គទាំងនេះ ប្រសិនបើយើងចង់ចៀសវាងកំហុសផ្សេងៗដែលនឹងអាចធ្វើឱ្យទាំងគ្រូ និង សិស្សអាចប្រឈមក្នុងការអនុវត្តវិធីនេះ។

រឿងដំបូងដែលត្រូវពិចារណានោះគឺអត្ថប្រយោជន៍ និងដែនកំណត់នៃការ អនុវត្តវា។ វិធីសម្ដែងតួគឺល្អសម្រាប់ពង្រឹងជំនាញដែលសិស្សមានរួចហើយ ប៉ុន្តែមិនសមស្របនៅពេលចាប់ផ្ដើមមេរៀនថ្មីនោះទេ។ ដោយសារវិធីនេះ អាស្រ័យលើភាពច្នៃប្រតិដ្ឋរបស់សិស្សទាំងស្រុងតែម្ដង ដែលជួនកាលពួកគេ អាចបង្កើតរឿងដែលមិននឹកស្មានដល់ តាមរយៈនៃការប្រើវាក្យសព្ទ និងឃ្លា ដែលខុសពីការរំពឹងទុក។ គ្រូបង្រៀនគួរប្រុងប្រយ័ត្នប្រសិនបើចង់ឱ្យសិស្ស អនុវត្តជំនាញ និងចំណេះដឹងជាក់លាក់ណាមួយ។ វិធីសម្ដែងតួចាំបាច់ សម្រាប់អនុវត្តជំនាញនិយាយ។ ប៉ុន្តែវាគួរតែត្រូវបានផ្សារភ្ជាប់ជាមួយគោល វិធី និងសកម្មភាពផ្សេងទៀត រួមទាំងការបង្រៀនដោយផ្ទាល់។ ជាទូទៅ វិធី សម្ដែងតួត្រូវបានប្រើនៅចុងបញ្ចប់នៃមេរៀននីមួយៗ វិធីសាស្ត្របង្រៀន ដោយបន្ថយឥទ្ធិពលគ្រូតែបង្កើនស្វ័យភាពសិស្ស (Release of Control) អាចធ្វើឱ្យគ្រូបង្រៀនភ័យខ្លាច។ ដូចជាវិធីសាស្ត្របង្រៀនតាមបែបស្ថាបនា និយមឬសិស្សមជ្ឈមណ្ឌលក៏ដោយ វិធីសម្ដែងតួ តម្រូវឱ្យគ្រូបង្រៀនកាត់ បន្ថយការគ្រប់គ្រងមួយចំនួនលើដំណើរការសិក្សា ដើម្បីផ្ដល់សិទ្ធិអំណាច ដល់សិស្សរបស់ខ្លួន។ នេះអាចធ្វើឱ្យគ្រូមានអារម្មណ៍មិនសូវស្រួលពេលប ង្រៀន។ មានហានិភ័យខ្ពស់នៃភាពបរាជ័យ ប្រសិនបើវិធីសម្ដែងតួមិនត្រូវ

បានរៀបចំឱ្យបានត្រឹមត្រូវ ឬប្រសិនបើសិស្សមិនបានដាក់ចិត្តបានត្រឹមត្រូវ ដើម្បីចូលរួមក្នុងសកម្មភាពនេះ។ ទាក់ទងនឹងផលជះនៃការគ្រប់គ្រងថ្នាក់រៀន លទ្ធផលរៀន និងបង្រៀនអាចប្រែប្រួល។ ខណៈពេលដែលវាអាចផ្តល់ភាពធូរស្រាលដល់គ្រូបានខ្លះក៏ដោយ វាក៏អាចពិបាកក្នុងការគ្រប់គ្រងសម្រាប់គ្រូផ្សេងទៀតផងដែរ។ ម្យ៉ាងវិញទៀត វិធីសម្តែងតួផ្តល់ឱ្យសិស្សនូវខ្លឹមសាររួមនៃគោលបំណងក្នុងមេរៀន ហើយពួកគេអាចរីករាយនឹងសកម្មភាពនេះច្រើនជាងធ្វើលំហាត់វេយ្យាករណ៍ទៅទៀត។ ម្យ៉ាងទៀត ប្រសិនបើការសម្តែងតួមិនត្រូវបានរៀបចំឱ្យបានត្រឹមត្រូវ វាក៏អាចបង្កើតស្ថានភាពអាម៉ាស់ ឬគ្រាន់តែបង្កភាពរញ៉េរញ៉ៃក្នុងថ្នាក់។ នៅក្នុងឧបសម្ព័ន្ធខាងក្រោម យើងបានកំណត់សេណារីយ៉ូដែលអាចពិបាកអនុវត្ត និងការប្រុងប្រយ័ត្នផ្សេងៗដែលគួរតែយកចិត្តទុកដាក់ ពេលប្រើប្រាស់សកម្មភាពសម្តែងតួក្នុងវិធីសាស្ត្របង្រៀន។

ការផ្តល់មតិយោបល់ លើសកម្មភាពសម្តែងតួ ក៏ជាបញ្ហាប្រឈមជាងការផ្តល់មតិទូទៅចំពោះសកម្មភាពផ្សេងទៀតក្រៅពីការសម្តែង ព្រោះក្នុងការសម្តែង សិស្សអាចនឹងផ្តល់ចម្លើយដែលមិននឹកស្មានដល់។ ទោះជាយ៉ាងណាក៏ដោយ វាអាចធ្វើទៅបានសិនបើមានការត្រៀមខ្លួនទុកជាមុន។ គ្រូបង្រៀនឆ្លាត ស្រាវជ្រាវប្រធានបទលើសពីអ្វីដែលពួកគេមានបំណងបង្រៀនសិស្ស។ ពួកគេព្យាយាមរៀបចំកំណត់ចំណាំមួយចំនួនទុកបម្រុង ដើម្បីឆ្លើយសំណួរដែលអាចព្យាករណ៍បាន ឬគ្រាន់តែដើម្បីបង្កើនចំណេះដឹងផ្ទាល់ខ្លួន។ ក្នុងករណីនេះ វិធីងាយៗសម្រាប់គ្រូបង្រៀនដែលមិនសូវចេះភាសាអង់គ្លេសគឺសាមញ្ញណាស់។ ដោយគ្រាន់តែ រៀបចំបញ្ជីវាក្យសព្ទមួយចំនួនបន្ថែមទៀត

ហើយរៀបចំសម្ភារៈមួយចំនួនដើម្បីណែនាំការសន្ទនា។ ឧទាហរណ៍ ក្នុងវិធីសម្ដែងតួ ការទិញបន្លែនៅផ្សារ អ្នកអាចរៀបចំផ្ទាំងក្រដាសមានរូបភាពបន្លែដែលអ្នកចង់ឱ្យសិស្សប្រើពេលនិយាយ បូករួមនឹងរូបភាពបន្លែបន្តិចបន្តួចទៀតដែលអ្នកបម្រុងទុក ដើម្បីបង្កើនភាពសម្បូរបែបនៃសកម្មភាពប្រសិនបើការសម្ដែងនោះមានដំណើរការល្អខ្លាំង។

ការគ្រប់គ្រងពេលវេលាមិនមែនជាលេសល្អទេ សម្រាប់ការមិនអនុវត្តការសម្ដែងតួនោះ។ តាមពិតនៅពេលសកម្មភាពសម្ដែងតួត្រូវបានរៀបចំឡើងយ៉ាងល្អ វិធីសម្ដែងតួបង្កើនពេលវេលានិយាយរបស់សិស្ស បើប្រៀបធៀបជាមួយតិចនិកផ្សេងទៀត។ ការពិភាក្សាក្នុងថ្នាក់ដែលដឹកនាំដោយគ្រូ នឹងផ្ដល់ឱ្យសិស្សម្នាក់ៗនូវពេលវេលាជាមធ្យមត្រឹមតែ ១ ឬ ២ នាទីដើម្បីនិយាយប៉ុណ្ណោះ ដូចដែលខ្ញុំបានពន្យល់នៅខាងលើ។ នេះច្បាស់ជាមិនគ្រប់គ្រាន់ទេសម្រាប់ការអនុវត្តជំនាញនិយាយដែលកំណត់ម៉ត់ចត់ក្រោមលក្ខខណ្ឌណាមួយ។ ផ្ទុយមកវិញ សិស្សមួយគូអាចរៀបចំវិធីសម្ដែងតួក្នុងពេលដំណាលគ្នា។ ជំនួសឱ្យ១នាទីសម្រាប់សិស្សម្នាក់ៗ វាអាចផ្ដល់ឱ្យពួកគេនូវពេលវេលា ១៥នាទីដើម្បីនិយាយជាមួយមិត្តរួមថ្នាក់ ឬប្រហែលជាច្រើនជាងនេះចំពោះសិស្សដែលបានស៊ាំនឹងសកម្មភាពនេះ។ ក្រៅពីនេះវិធីសម្ដែងតួមានប្រយោជន៍ខ្លាំង ដែលវាសមហេតុផលក្នុងការលះបង់ពីការធ្វើលំហាត់ផ្សេងៗមួយចំនួនដើម្បីអនុវត្តវាជំនួស។

វិធីសម្ដែងតួ គឺជាសកម្មភាពស្មុគស្មាញ ឬ ជាសកម្មភាពផ្ដល់ខ្លឹមសាររួម ព្រោះវាតម្រូវឱ្យមានចំណេះដឹងក្នុងកម្រិតផ្សេងៗ៖ ពាក្យ វេយ្យាករណ៍ ជាដើម ហើយគ្រូមួយចំនួនប្រហែលជាគិតថា សិស្សរបស់ខ្លួនមិនទាន់ពូកែគ្រប់

គ្រាន់។ ប៉ុន្តែវាគ្រាន់តែជាបញ្ហានៃការរៀបចំតែប៉ុណ្ណោះ។ ជាការពិតណាស់ចំណេះដឹងចាំបាច់គួរតែត្រូវបានផ្តល់ជាមុន។ មុនអនុវត្តវិធីនេះ វាចាំបាច់ក្នុងការណែនាំឱ្យគ្រូសង្ខេបចំណុចសំខាន់ៗដល់សិស្ស។ ល្បែងដោយប្រើពេល ៥នាទីជាមួយប័ណ្ណពាក្យនឹងធ្វើឱ្យសិស្សចងចាំពាក្យដែលខ្លួនបានរៀនពីមេរៀនមុនៗ។ ឬល្បែងហ្វឹកហាត់នឹងរំលឹកឡើងវិញនូវរចនាសម្ព័ន្ធវេយ្យាករណ៍ដែលចាំបាច់(មើលខាងក្រោម)។

*ឧទាហរណ៍៖ ចំពោះសិស្ស ភាពអៀនខ្មាសគឺជាឧបសគ្គចម្បង។ បញ្ហានេះក៏នឹងត្រូវបានដោះស្រាយក្នុងរឿងមួយដាច់ដោយឡែកផ្សេងទៀត។*

ជាចុងក្រោយ វាពិតជាលំបាកណាស់ក្នុងការបង្កើតការសន្ទនាដោយស្វ័យប្រវត្តិ។ តាមពិតទៅ អ្នកសម្តែងល្អ តែងយល់ពីខ្លឹមសាររួមនៃសាច់រឿង ជាពិសេសតួអង្គនីមួយៗក្នុងសាច់រឿង ដែលខ្លួនបានទន្ទេញយ៉ាងស្ទាត់ ហើយពួកគេប្រើវាដើម្បីបង្កើតស្ថានភាពសម្តែងបានយ៉ាងល្អប្រសើរ។នេះមានន័យថាអ្នកសម្តែងតួ គួរតែមានពេលវេលាគ្រប់គ្រាន់ដើម្បីហ្វឹកហាត់ពីប្រធានបទមុនពេលចូលខ្លួនសម្តែងនៅក្នុងថ្នាក់។ ករណីមានសកម្មភាពសម្តែងណាមួយមានភាពស្មុគស្មាញ តម្រូវឱ្យគ្រូមានពេលវេលារៀបចំវាបានហ្មត់ចត់។ ការរៀបចំនេះហាក់មិនបង្កផលលំបាកដល់គ្រូដែលមានសមត្ថភាពក្នុងរឿងនេះនោះទេ។

## ការហ្វឹកហាត់វាក្យស័ព្ទនិងវេយ្យាករណ៍

ចំណេះដឹងមូលដ្ឋានគួរតែមានភាពច្បាស់លាស់ ដោយមិនតម្រូវឱ្យមានការផ្ទុះបញ្ចាំងច្រើនដើម្បីប្រើពេលទៅរកការរំលឹកមេរៀនម្តងទៀត។ កម្រិតនៃភាពស្ទាត់ជំនាញនឹងមិនអាចសម្រេចបានក្នុងពេលត្រឹមមួយម៉ោងបានទេ ប៉ុន្តែអ្នកមិនចាំបាច់រង់ចាំរហូតដល់ចំណេះដឹងខាងវេយ្យាករណ៍ល្អឥតខ្ចោះ មុននឹងរៀបចំវិធីសម្តែងតួនោះឡើយ។

វាជាការល្អក្នុងការហាត់សមមេរៀនដែលទាក់ទងទៅនឹងប្រធានបទដែលកំពុងសិក្សា។ ជាឧទាហរណ៍ ការពិនិត្យចំនួនតួអង្គឡើងវិញ នឹងជួយសិស្សដើរតួដូចជា តួជាអ្នកលក់ និងជាអតិថិជនអំពីការទិញដូរក្នុងរយៈពេល១ម៉ោង។ វាអាចធ្វើឡើងប៉ុន្មាននាទីមុនការសម្តែង។ ប្រសិនបើអ្នកបង្រៀនពាក្យថ្មីៗក្នុងឱកាសសម្តែងនេះ នោះវាមានសារៈសំខាន់ដើម្បីឱ្យសិស្សបានហ្វឹកហាត់បន្តិចបន្តួចបន្ថែមទៀត។ ការហ្វឹកហាត់ទទួលបានចំណេះដឹងជាមូលដ្ឋានមិនមែនជារឿងលំបាកទេ តែតាមពិតទៅ នៅពេលវាត្រូវបានធ្វើឡើងដោយមានគោលបំណង និងការខិតខំប្រឹងប្រែងបានត្រឹមត្រូវ។ មានវិធីជាច្រើនដើម្បីធ្វើវា រួមទាំងការប្រើល្បែងសិក្សា និងនីតិវិធីជាច្រើនទៀត។ យើងមិនមានពេលគ្រប់គ្រាន់ដើម្បីរៀបរាប់លម្អិតអំពីជម្រើសទាំងអស់នៅក្នុងកូនសៀវភៅនេះទេ ប៉ុន្តែយើងនឹងផ្តល់នូវគំនិតសាមញ្ញមួយចំនួនសម្រាប់អ្នកយកទៅចាប់ផ្តើមសាកល្បង។

**គោលការណ៍ទីមួយ គឺរក្សាលំហូរនៃសកម្មភាព។** វិធីសម្តែងតួ គួរតែធ្វើឱ្យលឿន និងចំណាយពេលតិចតែប្រសិទ្ធភាព។ គ្រូគួរតែរៀបចំសំណួររបស់ខ្លួនទុកជាមុន ទោះបីជាសំណួរមានភាពសាមញ្ញក៏ដោយ និងមាននីតិ

វិធីច្បាស់លាស់ដើម្បីសួរសិស្ស។ កំហុសទូទៅមួយគឺភាពស្ទាក់ស្ទើរនៅពេលជ្រើសរើសសិស្សដើម្បីឆ្លើយសំណួរ។

**គោលការណ៍ទីពីរ គឺត្រូវធ្វើឱ្យសិស្សទាំងអស់ចូលរួមយ៉ាងសកម្ម។** ការប្រើក្តារឆ្នួនមានប្រសិទ្ធភាពខ្លាំងណាស់ ព្រោះសិស្សទាំងអស់អាចបង្ហាញចម្លើយខ្លួនក្នុងពេលតែមួយបាន។ ចំពោះសកម្មភាពធ្វើផ្ទាល់ អ្នកត្រូវស្តាប់ពីរបៀបដែលពួកគេអានពាក្យ។ អ្នកអាចឱ្យសិស្សអានពាក្យជាក្រុម បន្ទាប់មកហៅសិស្សពីរឬបីនាក់ឱ្យអានជាលក្ខណៈបុគ្គល ហើយក្រោយមកក៏ឱ្យពួកគេអានជាក្រុមម្តងទៀត។ ឆ្លាស់សកម្មភាពពីម្នាក់មកក្រុមបែបនេះត្រូវធ្វើឱ្យបានឆាប់រហ័ស។ ហៅសិស្សដោយចៃដន្យ ដោយការហៅរយៈការប្រើកាយវិការ (ចង្អុលរាប់) ដើម្បីបញ្ចៀសការខ្ជះខ្ជាយពេលវេលា និងធានាថា សិស្សគ្រប់គ្នានៅតែមានស្មារតីរស់រវើក។ សិស្សទាំងនោះមិនគួរដឹងជាមុនទេថាម្នាក់ណានឹងត្រូវគ្រូហៅសួរ។ ពិតណាស់ ការហ្វឹកហាត់ជាដៃគូ ដោយប្រើប័ណ្ណពាក្យក៏ជាវិធីមានប្រសិទ្ធភាពមួយដើម្បីធ្វើឱ្យសិស្សទាំងអស់បានចូលរួមផងដែរ។

**គោលការណ៍ទីបី** គឺ **ការសាកល្បងសម្តែងតួ។** សិស្សត្រូវតែព្យាយាមយកចំណេះដឹងដែលមានស្រាប់មកប្រើពេលសម្តែង ព្រោះការសម្តែងត្រូវការពេលហាត់សមសមស្រប និងតម្រូវឱ្យតួអង្គមានកាយវិការ ចងចាំតួនាទី និងសម្តីដែលត្រូវនិយាយ មានភាពបត់បែន និងតម្រូវតាមកាលៈទេសៈ។ បើការសម្តែងនោះធ្វើតាមអ្វីដែលគេទើបតែនិយាយ ឬសមក្នុងរយៈខ្លីពេក នឹងមិនមានប្រសិទ្ធភាពខ្លាំងក្លានោះទេ។

**គោលការណ៍ទីបួន** គឺ **ការហាត់សម្តែងដោយមានគម្លាត។** ផ្អែកតាមការ

ស្រាវជ្រាវមួយចំនួនអំពីការចងចាំ បានបញ្ជាក់ថា ការប្រើរយៈពេលខ្លីហ្វឹកហាត់បានទៀងទាត់មានប្រសិទ្ធភាពជាជាងការហ្វឹកហាត់ប្រើពេលយូរមុនពេលត្រូវសម្តែង។ ម្យ៉ាងទៀត វាជារឿងប្រសើរកាលដែលបានអនុវត្តត្រឹមពេល៥នាទីនៅដើមនៃមេរៀនរៀងរាល់ថ្ងៃ ជាជាងចំណាយពេលមួយម៉ោងតាមពេលនីមួយៗ។

## គោលការណ៍ស្តង់ដាពេលអនុវត្តវិធីសម្តែងតួ

"បន្ទាប់ពីឈុតឆាកបានត្រៀមរួចរាល់ នោះយុទ្ធវិធីស្តង់ដាក្នុងការរៀបចំវិធីសម្តែងតួគឺជារឿងសាមញ្ញបំផុត។"

### ១) ផ្តល់ប្រធានបទដល់សិស្ស ហើយបើអាច គួរភ្ជាប់ជាមួយរូបភាពគាំទ្រផងដែរ។

វាជារឿងល្អ ប្រសិនបើឱ្យសិស្សម្នាក់បកប្រែប្រធានបទដោយមានភ្ជាប់រូបភាពជំនួយ ទៅជាភាសាកំណើតរបស់ខ្លួន ដើម្បីពិនិត្យមើលថាតើសិស្សផ្សេងទៀតយល់ដឹងពីប្រធានបទនោះដែរឬទេ។ គាត់មិនចាំបាច់ផ្តល់ពន្យល់ច្រើនពេកទេ ដោយគ្រាន់តែធ្វើប្រែវាតាមរយៈភាសាសាមញ្ញ ហើយបង្កើនទុកចិត្តលើការស្រមើស្រមៃរបស់ខ្លួន។

### ២) ផ្តល់ពេល ១៥ នាទី ឬច្រើនជាងនេះដល់សិស្សដើម្បីអនុវត្តការសន្ទនាជាគូ (ឬជាក្រុមតូចៗប្រសិនបើមានតួនាទីច្រើនជាងពីរនៅក្នុងសេណារីយ៉ូ)

អ្នកគួរអនុញ្ញាតឱ្យសិស្សសាកល្បងដោយមិនជ្រៀតជ្រែករយៈពេល ៥ នាទីរហូតដល់ពួកគេទាំងអស់ចូលរួម។ បន្ទាប់ពីបានចំណាយពេល៥នាទីរួចអ្នកចាប់ផ្តើមត្រួតពិនិត្យថ្នាក់។ ចូរប្រាកដថាគ្មានក្រុមណាមួយអសកម្ម និងឆ្លើយសំណួរនៅក្នុងក្រុមនីមួយៗផ្សេងៗគ្នានោះទេ។ ព្យាយាមកុំរំខានពួកគេ

ខណៈកំពុងអនុវត្តបានល្អរួចហើយ។ តាមរយៈនៃការធ្វើបែបនេះ គ្រូបង្រៀនដើរតួជាអ្នកសម្របសម្រួល ដូចដែលបានបង្ហាញនៅក្នុងទ្រឹស្តីស្ថាបនានិយម។ សិស្សអាចប្រើវចនានុក្រម ឬឯកសារផ្សេងទៀតមកជំនួយ។ ប្រសិនបើពួកគេជាសិស្សឧស្សាហ៍ព្យាយាម នោះអ្នកអាចពិចារណាដោយឱ្យប្រើទូរស័ព្ទស្មាតហ្វូនដើម្បីស្វែងរកគំនិតបន្ថែមនៅលើប្រព័ន្ធអ៊ីនធឺណិត។ ចំពោះសិស្សពូកែត្រូវបានរំពឹងថានឹងធ្វើការសន្ទនាលម្អិតជាង ដូច្នេះពួកគេគួរតែផ្តល់ពេលវេលា និងធនធានច្រើនជាងមុនដើម្បីរៀបចំ។

**៣) ផ្អាកដំណាក់កាលរៀបចំ ហើយងាកមកទាញចំណាប់អារម្មណ៍របស់សិស្សវិញ។** ប្រាប់សិស្សឱ្យស្តាប់មិត្តរួមថ្នាក់របស់ខ្លួន។ វាពិតជាល្អជាងប្រសិនបើអ្នកចូលរួមមានអ្វីមួយត្រូវធ្វើ។ជាឧទាហរណ៍ ពួកគេអាចសរសេរជាសំណួរ ឬការសង្កេតរបស់ខ្លួនក្នុងអំឡុងពេលសម្តែង។ ប៉ុន្តែចូរប្រាប់ពួកគេមិនចាំបាច់ចម្លងអ្វីដែលអ្នកសរសេរនៅលើក្តារខៀនឥឡូវនេះក៏បានដែរ ពីព្រោះសំណេរអាចនឹងមានកំហុសខ្លះៗ។

**៤) ចូរជ្រើសរើសក្រុមដំបូងគេ។** វាជារឿងសំខាន់កាលដែលមិនបានប្រាប់ថាក្រុមណានឹងត្រូវបានជ្រើសជាក្រុមសម្តែងដំបូងគេ។ ដូច្នេះគ្រប់ក្រុមទាំងអស់ត្រូវតែរៀបចំដោយខ្លួនឯង។ វាជាការណែនាំឱ្យជ្រើសរើសក្រុមល្អមួយសម្តែងជាមុនដោយឡែកក្រុមខ្សោយចាំពេលក្រោយ។

**៥) នៅពេលក្រុមកំពុងសម្តែង សូមកត់ត្រានៅលើក្តារខៀន ដើម្បីទុកជាមតិកែលម្អនៅពេលក្រោយ។** តើអ្នកគួរកត់ត្រាអ្វីខ្លះ? គ្រប់រឿងដែលគួរឱ្យចាប់អារម្មណ៍ ទាំងវិជ្ជមាន និងអវិជ្ជមាន៖ចំណុចដែលត្រូវកែលម្អ គំនិតល្អៗ, ពាក្យពេចន៍បន្ថែម ប្រសិនបើវាអាចជួយឱ្យស្ថានភាពកាន់តែប្រសើរ

(ឧទាហរណ៍ ពាក្យដែលពួកគេកំពុងព្យាយាមស្វែងរក ។ល។) ព្យាយាម **កុំរំខាន** ពេលពួកគេកំពុងសម្តែងដោយឱ្យពួកគេធ្វើខុសដោយសេរី។ កុំផ្តាច់សង្វាក់សម្តែងរបស់ពួកគេ។

**៦. ផ្តល់មតិកែលម្អ។ ដំបូង** ថ្លែងអំណរគុណដល់ក្រុមសម្តែង និងសរសើរដល់ពួកគេចំពោះអ្វីដែលធ្វើល្អពេលឡើងសម្តែង។ ផ្តល់ការលើកទឹកចិត្ត បើពួកគេជួបការលំបាក។ បន្ទាប់មកទៀត សុំឱ្យមិត្តរួមថ្នាក់(អ្នកទស្សនា) ចូលរួមផ្តល់មតិយោបល់បែបស្ថាបនាដល់ការសម្តែងរបស់ពួកគេ។ ជា**ចុងក្រោយ** អ្នកអាចបន្ថែមជាមតិរបស់ខ្លួន។ ចូរកុំកែតម្រូវគ្រប់ចំណុច (គ្រប់រឿង)។

**៧. ឱ្យសិស្សកត់ត្រាគំនិតគួរឱ្យចាប់អារម្មណ៍ទុកក្នុងសៀវភៅ** នៅពេលអ្នកបានលុបសំណេរកត់ត្រាពីកំហុសទាំងអស់នៅលើក្តារខៀនរួចហើយ។

ប្រសិនបើមានមតិច្រើនចំពោះការសម្តែង ចូរជ្រើសរើសតែអ្វីដែលសំខាន់ ឬអាចអនុវត្តបានដោយយកតែ**៥ ចំណុចសំខាន់** គឺគ្រប់គ្រាន់។ អ្នកអាចឱ្យក្រុមសម្តែងជ្រើសរើសចំណុចដែលខ្លួនគិតថាសំខាន់បំផុត។ សម្រាប់ព័ត៌មានលម្អិតពេញលេញអំពីការផ្តល់មតិយោបល់ សូមមើលជំពូកឬផ្នែកដែលផ្តោតជាពិសេស។

**វិធីដោះស្រាយជាមួយនឹងភាពខ្មាសអៀន**?

ជំហានដំបូងដើម្បីដោះស្រាយភាពអៀនខ្មាសរបស់សិស្ស គឺគ្រូត្រូវបង្ហាញការសម្តែងដល់សិស្សជាមុនសិន ឬសម្តែងជាមួយសិស្សដើម្បីបន្សាំភាពខ្មាសអៀនរបស់ពួកគេ មុននឹងសម្តែងជាផ្លូវការ ការសម្តែងពិតណាស់ ភាពខ្មាសតែងកើតឡើងពេលដែលវាជាការចាប់ផ្តើមដំបូងរបស់ពួកគេ និងរាប់ថាជារឿងធម្មតា។ គោលបំណងនៃថ្នាក់ភាសាអង់គ្លេសគួរតែបានដឹងច្បាស់សម្រាប់មនុស្សគ្រប់គ្នា៖ នៅចុងបញ្ចប់នៃវគ្គសិក្សា សិស្សទាំងអស់គួរតែអាចនិយាយជជែកជាភាសាអង់គ្លេសបាន។ ហើយដើម្បីសម្រេចបានដូចនេះ ពួកគេត្រូវតែហាត់និយាយ។ ពួកគេនឹងចាប់ផ្តើមអនុវត្តជាមួយការសន្ទនាប្រចាំថ្ងៃងាយ ប៉ុន្តែពួកគេត្រូវតែធ្វើវាឱ្យបានទាំងអស់គ្នា។ បន្តិចម្តងៗ ការធ្វើបែបនេះនឹងក្លាយជាទម្លាប់។

កំណត់វិន័យឱ្យច្បាស់លាស់តាំងពីដើមទី ហើយកុំខ្លាចក្នុងការរំលឹកសិស្សឡើងវិញរាល់ពេលដែលចាំបាច់។ វិន័យទីមួយ ជាការពិតណាស់ គឺត្រូវស្តាប់នៅពេលមិត្តរួមថ្នាក់កំពុងធ្វើសកម្មភាព។ ស្នើឱ្យសិស្សកត់ត្រានឹងជួយឱ្យពួកគេផ្តោតអារម្មណ៍បានល្អ។ វិន័យទីពីរគឺត្រូវអធ្យាស្រ័យចំពោះកំហុស និងមិនត្រូវសើចចំអកដាក់មិត្តរួមថ្នាក់នោះទេ។ បើមិនដូច្នេះទេ មិត្តរួមថ្នាក់នឹងសើចចំអកដាក់ខ្លួនវិញជាក់ជាពុំខាន។ មនុស្សគ្រប់គ្នាសុទ្ធតែធ្វើខុសព្រោះនេះជារឿងធម្មតា។ កុំធ្វើចំពោះអ្នកដទៃនូវអ្វីដែលអ្នកមិនចង់ឱ្យអ្នកដទៃធ្វើចំពោះខ្លួន។ ប្រសិនបើអ្នកស្នើឱ្យសិស្សកត់ត្រា និងចែករំលែកការសង្កេតរបស់ខ្លួនគួរពន្យល់ថាអ្វីទៅជាការរិះគន់បែបស្ថាបនា។

ការរិះគន់បែបស្ថាបនា មិនត្រឹមតែនិយាយពីអ្វីដែលខុសនោះទេ ប៉ុន្តែក៏ត្រូវ

លើកឡើងពីចំណុចល្អៗផងដែរ ហើយវាតែងតែធ្វើឡើងដោយសមានចិត្ត ដើម្បីជួយកែលម្អការសម្តែង។ ជាការពិត ក្រោមលក្ខខណ្ឌខ្លះ គ្រូបង្រៀន ចាំបាច់បញ្ជាក់ពីដែនកំណត់នៃការរិះគន់បែបស្ថាបនាចំពោះសិស្សមួយ ចំនួនដែលមានឥរិយាបថផ្តាំផ្តង។ ប៉ុន្តែបន្ទាប់ពីប៉ុន្មានម៉ោងក្រោយមក វាគួរ តែមិនមែនជាបញ្ហាទៀតនោះទេ។ និយាយអីចឹង ការរកឃើញដែនកំណត់ ទាំងនោះគឺជាជំនាញសង្គមដ៏សំខាន់ក៏ដូចជាការទទួលយកការរិះគន់ផងដែ រ។ ចាប់ផ្តើមសកម្មភាពជាមួយសិស្សដែលមានទំនុកចិត្ត។ ការណែនាំនេះ មានសុពលភាពសម្រាប់កិច្ចការដែលថ្មីហើយពិបាកតែមិនមែនគ្រាន់តែជា ការសម្តែងឱ្យតែបានៗប៉ុណ្ណោះទេ។ ត្រូវប្រាកដថាក្រុមទីមួយគឺជាក្រុមដែល ល្អ។ ពួកគេនឹងបង្ហាញពីលទ្ធភាពនៃការសម្តែង បង្កើតទស្សនីយភាពដល់ អ្នកមើលបង្កើនការរំពឹងទុកដល់កម្រិតដែលអាចទទួលយកបាន និងផ្តល់ ឧទាហរណ៍ដែលអ្នកដទៃអាចយកតម្រាប់តាម។ លើកទឹកចិត្តជាពិសេស នៅពេលដែលអ្នក កែកំហុសរបស់សិស្ស។ ចូររក្សាឥរិយាបថវិជ្ជមាន។ ការ និយាយពិតជាងាយស្រួលជាងធ្វើ។ ជារឿយៗ គ្រូមិនគួរប្រើពាក្យពេចន៍ បង្អាប់សិស្សរបស់ខ្លួននៅពេលដែលពួកគេនិយាយថា៖ «អ្នកអាចធ្វើវាបាន» ។ សិស្សខ្លះមើលមិនឃើញពីរបៀបធ្វើ។ ចូរបង្ហាញឱ្យឃើញពីកំហុសរបស់ ពួកគេជាបំណងប្រាថ្នាដែលទាញការចាប់អារម្មណ៍។ ចូរធ្វើរឿងទាំងនោះឱ្យ បានហ្មត់ចត់។ មើលអ្វីដែលសិស្សបានព្យាយាមសម្រេច មិនមែនជាអ្វីដែល អ្នកនឹងធ្វើជំនួសពួកគេនោះទេ។ ជាឧទាហរណ៍នៅក្នុងសេណារីយ៉ូមួយ ដែលសិស្សប្រើលេសប្រាប់នាយកសាលាតែវាមិនមានជាបញ្ហាទេប្រសិនបើ អ្នករកលេសមិនគួរឱ្យជឿ។ គ្រាន់តែប្រាប់ពីពាក្យពេចន៍ (ខ្លឹមសារ) ដែល

គាត់ត្រូវនិយាយនូវអ្វីដែលគាត់ចង់ឱ្យដឹងដូចក្នុងឧទាហរណ៍មួយខាងក្រោម ។ មានសត្វពពែមួយក្បាលឃ្លានហើយបានដើរមកស៊ីសៀវភៅរបស់ប្អូនប្រុសពៅរបស់គាត់ (សិស្សដែលកំពុងប្រាប់នាយកសាលា) និងបន្ថែមថា ស្របពេលនោះមានក្មេងជើងកាងមួយហ្វូង បានគប់ដុំថ្មដាក់គាត់ពេលកំពុងនៅតាមផ្លូវមកសាលារៀន (ធ្វើតាមវិធីនេះ ជាសេណារីយ៉ូមួយដែលអាចជឿទុកចិត្តបាននៅបណ្ដាប្រទេសមួយចំនួន)។ ចាប់ផ្ដើមអនុវត្តសេណារីយ៉ូដែលមានភាពសាមញ្ញ និងងាយស្រួល។ គ្រូខ្លះប្រហែលជាគិតថាវិធីសម្ដែងតួមានភាពស្មុគស្មាញខ្លាំងចំពោះអ្នក សម្ដែងជាលើកដំបូង។ ការយល់ឃើញបែបនេះមិនមែនជាការពិតនោះទេ។ ដូចដែលអ្នកនឹងបានយល់នៅក្នុងសេណារីយ៉ូដែលយើងលើកជាគំនិតនៅចុងបញ្ចប់នៃកូនសៀវភៅនេះ ដោយវាពិតជាអាចទៅរួចក្នុងការអនុវត្តសកម្មភាពសាមញ្ញមួយចំនួនបន្ទាប់ពីអ្នកបានបង្រៀនពីរបីសប្ដាហ៍។ ស្ថានភាពជីវិតពិតខ្លះមិនតម្រូវឱ្យមានការប្រើប្រាស់រចនាសម្ព័ន្ធវេយ្យាករណ៍ស្មុគស្មាញទេ ប៉ុន្តែជាការប្រើប្រាស់ពាក្យពេចន៍មួយចំនួនឱ្យបានត្រឹមត្រូវតែប៉ុណ្ណោះ។ ម្យ៉ាងទៀត វិធីសម្ដែងតួមិនចាំបាច់ប្រើពេលវេលាច្រើនពេកនោះទេ (អាស្រ័យលើទំហំនៃសាច់រឿង)។ ការសម្ដែងដោយប្រើពេលខ្លី ត្រឹម៣នាទីគឺគ្រប់គ្រាន់ដើម្បីផ្ដល់ការហ្វឹកហាត់សមស្របដល់សិស្ស។ ចំពោះការសម្ដែងក្រោយៗទៀតការសន្ទនា នឹងកាន់តែមានលក្ខណៈសម្បូរបែប និងប្រើពេលច្រើនជាងមុន។ ជាការពិតណាស់ សិស្សនឹងសប្បាយរីករាយក្នុងការសម្ដែងតួអង្គជាឃាតករ និងជាមេធាវីនៅក្នុងការតុលាការកាត់ក្ដីបែបប្រតិដ្ឋ។ ប៉ុន្តែវាជាសមិទ្ធផលដ៏សំខាន់បានដែលបានធ្វើពីមុនរួចទៅហើយ ដែលអាចឱ្យសិស្សចេះទិញបន្លែនៅឯទីផ្សារតាម

រយៈការសម្ដែងលើកមុន។

ជាចុងក្រោយវាអាចជាការល្អក្នុងការសួរសិស្សថាតើពួកគេមានអារម្មណ៍យ៉ាងណាចំពោះសកម្មភាពសម្ដែងនេះ។ ការសាកសួរពីអារម្មណ៍ទាំងនេះអាចធ្វើឡើងដោយចំហ ឬផ្ទាល់នៅពេលមេរៀនបញ្ចប់ គឺជាល្បិចក្នុងការបង្រៀនរបស់គ្រូ។

## វិធីផ្ដល់មតិត្រឡប់ដល់សិស្ស

មានបញ្ហាសំខាន់៣ដែលអាចកើតឡើងនៅពេលអ្នកផ្ដល់មតិត្រឡប់ដល់សិស្សនៅក្នុងថ្នាក់រៀន៖

1. ភាពមិនស្រណុកស្រួលក្នុងចិត្ត
2. កង្វះភាពច្បាស់លាស់
3. ផ្ដល់មតិច្រើនពេក

វាមិនសមស្របនោះទេកាលដែលទទួលយកយោបល់ពីកំហុសរបស់អ្នក ជាពិសេសចំពោះមុខមិត្តរួមថ្នាក់ទាំងឡាយ។ ប៉ុន្តែវារឿងចាំបាច់ ហើយអាចរួមចំណែកដល់ការអប់រំសីលធម៌ដល់សិស្សគ្រប់គ្នា។ យ៉ាងណាមិញការទទួលយកទំនួលខុសត្រូវរបស់គេ និងព្យាយាមកែលម្អខ្លួនឯង គឺជាជំនាញសង្គមដ៏សំខាន់។ វាស្រដៀងទៅនឹងការប្រកួតដោយយុត្តិធម៌ និងទទួលយកភាពបរាជ័យនៅក្នុងល្បែងនោះ។ អ្វីដែលសំខាន់គឺត្រូវធ្វើឱ្យសិស្សមានទំនុកចិត្តគ្រប់គ្រាន់ដើម្បីទទួលយកការរិះគន់ក្នុងន័យស្ថាបនា។

ចូលបែងចែកឱ្យដាច់រវាងបុគ្គល និងការសម្ដែងរបស់គាត់។ មិនត្រូវផ្ដល់មតិត្រឡប់លើភាពឆោតល្ងង់របស់សិស្សនោះទេ។ ចូរកុំសន្និដ្ឋានបែបអវិជ្ជមាន

អំពីរឿងអនាគតរបស់សិស្សណាម្នាក់។ ចូរបន្តគំនិតរិះគន់របស់អ្នកឱ្យមានប្រយោជន៍ជានិច្ចចំពោះសិស្ស។ សូមប្រាកដក្នុងចិត្តថា ប្រសិនបើអ្នកចង្អុលពីកំហុស តែអ្នកក៏ផ្តល់នូវវិធីកែលម្អវាផងដែរ ដែលអាចស្តារវាឱ្យប្រសើរ និងមិនលើសពីសមត្ថភាពរបស់សិស្សនោះទេ។

មតិត្រឡប់ដែលល្អ នោះគឺនៅពេលដែលសិស្សបានធ្វើខុស ត្រូវផ្តល់ឱកាសឱ្យគាត់កែកំហុស។ គ្រូគ្រាន់តែនិយាយថាឃ្លានេះខុសកំណត់កំហុសផ្សេងៗ ហើយទុកឱ្យសិស្សបង្កើតទម្រង់ឱ្យបានត្រឹមត្រូវដោយខ្លួនឯង។

ជាការពិតណាស់ ចូរកុំសួរអ្វីដែលមិនអាចទៅរួច ប៉ុន្តែសម្រាប់កំហុសតូចតាច ការកែខ្លួនឯងគួរតែជាទម្លាប់ ។ យ៉ាងហោចណាស់ សិស្សបានបំពេញលើមតិត្រឡប់របស់គ្រូដោយជោគជ័យ។

រក្សារាល់ការពន្យល់ទាំងអស់ឱ្យសាមញ្ញ។ ប្រសិនបើសំណួរត្រូវការកែតម្រូវបន្ថែមទៀត ជាឧទាហរណ៍ដូចជាមេរៀនវេយ្យាករណ៍ដែលពិបាកចូរកត់ត្រាទុកហើយរៀបចំមេរៀននោះសម្រាប់ម៉ោងបង្រៀនពេលក្រោយ។

ស្រដៀងគ្នានេះដែរ ប្រសិនបើសិស្សសួរសំណួរស្មុគស្មាញដែលប្រាសចាកពីខ្លឹមសារនៃមេរៀន ឬ លើសពីចំណេះដឹងរបស់អ្នក អ្នកគ្រាន់តែប្រាប់ដល់ពួកគេថា មេរៀននេះ ឬសំណួរនេះទុកសម្រាប់ថ្ងៃក្រោយ។ នៅពេលវេលាមកដល់ តួនាទីជាគ្រូ គាត់ត្រូវពន្យល់ ឬផ្តល់ចម្លើយតាមការសន្យារបស់ខ្លួន។

អ្នកប្រហែលជាមានមតិច្រើនចង់និយាយ។ នៅពេលដែលអ្នកយល់ថា មតិទាំងនោះច្រើនលើសលប់សម្រាប់សិស្សក្នុងការដោះស្រាយសុំឱ្យអ្នកសម្តែងតួ (ជាសិស្ស) ជ្រើសរើសចំណុចសំខាន់ចំនួនពីរ ឬបី ដែលពួកគេចង់កែលម្អសម្រាប់ពេលសម្តែងលើកក្រោយ។ ការទទួលយកពីរ ឬបីចំណុច

សម្រាប់ការកែលម្អអាចថាល្មមគ្រប់គ្រាន់សម្រាប់ការសម្ដែងម្ដងៗ ។ ការធ្វើបែបនេះនឹងផ្ដល់កម្លាំងចិត្ត និងប្រសិទ្ធភាពដល់ពួកគេ និងចូលរួមកាន់តែផុសផុល និងស៊ីជម្រៅក្នុងការសិក្សារបស់ខ្លួន។ និយាយអីចឹង ការផ្ដល់ ស្នាមញញឹមដល់ពួកគេពេលសម្ដែង មិនធ្វើឱ្យខាតបង់អ្វីនោះទេ តែជាជំរុញទឹកចិត្តដ៏ប្រសើរ។

## តើត្រូវប្រើពេលប៉ុណ្ណាសម្រាប់ការសម្ដែងបែបធម្មជាតិ?

ការសម្ដែងបែបធម្មជាតិ គឺជាជំនាញដ៏លំបាកបំផុតក្នុងសិល្បៈល្ខោន។ ទោះយ៉ាងណាក៏ដោយ ជីវិតពិតខុសពីជីវិតលើឆាក។ នៅទីបំផុតអ្នកនឹងពិនិត្យមើលថាតើសិស្សរបស់អ្នកអាចប្រើពាក្យពេចន៍ក្នុងការសន្ទនាថ្មីមួយបានដោយរបៀបណា។ ប្រសិនបើពួកគេត្រូវជជែកជាមួយអ្នកទេសចរបរទេស នោះពួកគេនឹងគ្មានពេលវេលាគ្រប់គ្រាន់ដើម្បីរៀបចំការឆ្លើយតបរបស់ខ្លួនក្នុងស្ថានភាពនោះឡើយ។ពួកគេនឹងត្រូវនិយាយនៅនឹងកន្លែងតែម្ដង។ មេរៀនមិនមែនជាបទពិសោធក្នុងជីវិតពិតទេ ប្រាកដណាស់ប៉ុន្តែវាគួរតែរៀបចំសិស្សសម្រាប់ជីវិតជាក់ស្ដែង តាមរយៈអ្វីដែលយើងហៅថាវិធីសាស្ត្របង្រៀនដោយបន្ថយឥទ្ធិពលគ្រូតែបង្កើនស្វ័យភាពសិស្សជាប្រចាំ (Progressive release of responsibility)។ ដំបូងសេណារីយ៉ូមួយចំនួនអាចមានលក្ខណៈសិប្បនិម្មិតបន្តិចហើយពួកវានឹងត្រូវអនុវត្តតាមសម្ភារៈដែលបានរៀបចំទុកហើយសូម្បីតែជាមួយសម្ភារៈបែបរន្ទា (Scaffolding) មួយចំនួនដូចជាស្លាកវាក្យសព្ទជាដើម។ នៅក្នុងការសន្ទនាពួកគេនឹងឆ្លើយសំណួរតាមការរំពឹងទុកដូចដែលពួកគេបានរៀបចំទុកមុន។ ប៉ុន្តែជាមួយនឹងសិស្សពូកែ (សិស្សរៀនលឿន) អ្នកអាចណែនាំពីការលំបាកមួយចំនួន។

ជាឧទាហរណ៍ប្រសិនបើអ្នកមានអារម្មណ៍ ថាសិស្សត្រៀមរួចរាល់ហើយ អ្នកអាចប្តូរសិស្សពីដៃគូផ្សេងៗគ្នាឱ្យអនុវត្ត។ ជាទូទៅអ្នកអាចធ្វើវាបាននៅពេលសិស្សស្គាល់ពាក្យបំពេញ និងឃ្លានិយាយផ្សេងទៀត ដើម្បីផ្តល់ចម្លើយឆ្លើយតបដែលពិបាកយល់ដូចជា៖

- "ទុកពេលឱ្យខ្ញុំគិតអំពីវា" ។
- "តើអ្នកចង់មានន័យថាម៉េច?"
- "តើអ្នកអាចពន្យល់ពាក្យនេះបានទេ?"
- "ប្រាប់ខ្ញុំផង ប្រសិនបើខ្ញុំខុស"

កម្រិតស្មុគស្មាញនៃការសម្តែងអាចជាគ្រូ ជាតួអង្គក្នុងកិច្ចសន្ទនាដែលមិនបានគ្រោងទុកមុន ជាឧទាហរណ៍ សម្តែងជាសាក្សីនៅនាទីចុងក្រោយនៃការសម្តែងប្រតិដ្ឋ ឬជាអតិថិជនទីពីរដែលចង់ទិញទំនិញដូចគ្នានឹងតួអង្គម្នាក់ទៀត (សិស្ស)។ ឈុតសម្តែងនេះអាចបង្កភាពសប្បាយរីករាយ ហើយនឹងបានបង្ហាញពីជំនាញទំនាក់ទំនងកម្រិតខ្ពស់របស់សិស្សប្រសិនបើពួកគេមិនត្រូវបានរំខានតាមរយៈនៃការអន្តរាគមន៍ផ្សេងៗពីអ្នកពាក់ព័ន្ធ។ ប៉ុន្តែត្រូវចាំថា គោលបំណងនៃការសម្តែងនោះគឺផ្តល់អំណាចដល់សិស្ស មិនមែនដើម្បីបង្ហាញពីជំនាញការសម្តែងរបស់គ្រូនោះទេ។ ចូរសរសើរពួកគេកាលដែលចេះដោះស្រាយបញ្ហាប្រឈមរបស់ខ្លួនបាន។ ការសម្តែងកម្រិតស្មុគស្មាញនេះ អាចសម្រេចបាននៅចុងបញ្ចប់ថ្នាក់វិទ្យាល័យ ហើយវាមានន័យថាសិស្សបានត្រៀមខ្លួនរួចជាស្រេចក្នុងការប្រើប្រាស់ភាសាអង់គ្លេសនៅក្នុងជីវិតប្រចាំថ្ងៃរបស់ខ្លួន។

## ឧបករណ៍៖ សេណារីយ៉ូ

មានវិធីសម្ដែងតួជាច្រើនដែលគួរតែណែនាំនៅក្នុងសៀវភៅសិក្សាគោលមុខវិជ្ជាភាសាអង់គ្លេស។ ជាទូទៅ ក្នុងសៀវភៅនោះមានលេចឡើងជាប្រធានបទខ្លីមួយនៅចុងបញ្ចប់នៃមេរៀនមួយ៖

"សូមពិភាក្សាលើប្រធានបទមាននៅចុងបញ្ចប់

នៃមេរៀននីមួយៗ ជាមួយមិត្តរួមថ្នាក់របស់អ្នក ។ល។"

គ្រូបង្រៀនជាច្រើនមើលរំលងពីការប្រៀវិធីសម្ដែងតួទាំងនេះ ព្រោះសេចក្ដីណែនាំមិនមានការការពន្យល់លម្អិតអំពីវាដល់ពួកគេទេ។ ជាមួយនឹងគន្លឹះមួយចំនួនដែលមាននៅក្នុងកូនសៀវភៅនេះ អ្នកមិនគួរមានផលលំបាកក្នុងការអនុវត្តវាឡើយ។ នៅក្នុងផ្នែកចុងក្រោយនេះ យើងផ្ដល់ឱ្យអ្នកនូវសេណារីយ៉ូបន្ថែម ដោយមានចាត់ថ្នាក់ដើម្បីឱ្យអ្នកអាចយល់បានយ៉ាងងាយស្រួលពីរបៀបដែលប្រធានបទនីមួយៗអាចគាំទ្រដល់ការរៀនភាសាកាន់តែស៊ីជម្រៅ។ គ្រូបង្រៀនត្រូវបានណែនាំឱ្យបង្កើតសេណារីយ៉ូផ្ទាល់ខ្លួនដោយខ្លួនឯងល្អិកណាពួកគេដឹងពីលទ្ធផលសិក្សាដែលបានរំពឹងទុក។ សេណារីយ៉ូល្អៗទាំងនោះឆ្លុះបញ្ចាំងពីលទ្ធផលដែលបានរំពឹងទុក។ ដូចគ្នានេះផងដែរសេណារីយ៉ូល្អគួរតែមានភាពសាមញ្ញតែឆ្លើយតបចំពោះគោលបំណងនៃមេរៀន។ សេណារីយ៉ូទាំងនោះគួរតែសិស្សអាចធ្វើបានដោយគ្មានភាពស្មុគស្មាញ (ដូចជាការទិញអាហាររបស់អ្នក) ប៉ុន្តែក៏ផ្ដល់ឱ្យសិស្សនូវភាពច្នៃប្រតិដ្ឋផងដែរ (ដូចជាការជជែកអំពីគុណភាព នៃបន្លែឬចែករំលែកដំបូន្មានធ្វើម្ហូប)។

ជាទូទៅសេណារីយ៉ូគួរមានលក្ខណៈសាមញ្ញនិងបើកចំហគ្រប់គ្រាន់ដើម្បីផ្តល់សេរីភាពដល់អ្នកសម្តែងប្រកបដោយភាពច្នៃប្រតិដ្ឋបំផុត។ សេណារីយ៉ូល្អអាចបង្កឱ្យសិស្សត្រាប់តាមស្ថានភាពបានយ៉ាងងាយ។ ប៉ុន្តែត្រូវចាំថាសិស្សក៏ចូលចិត្តពីភាពរវើរវាយនិងចម្លែកផងដែរ។តុល្យភាពដ៏ល្អរវាងការស្គាល់ និងការស្រមើស្រមៃគឺជាអ្វីដែលបង្កើតរឿងដ៏អស្ចារ្យ។ នេះជារូបមន្តរបស់ ហ៊ារីផតធឺ (HarryPotter) ជាឧទាហរណ៍ក្មេងប្រុសធម្មតាម្នាក់ត្រូវបានយកទៅកាន់ពិភពអភិនីហារ។



## កម្រិតមូលដ្ឋាន

| ប្រធានបទ/ ជំនាញទំនាក់ទំនង | ការពិពណ៌នា | លទ្ធផលភាសាវិទ្យា (វេយ្យាករណ៍/ វាក្យសព្ទ) | កំណត់ចំណាំ |
|---|---|---|---|
| ការណែនាំខ្លួន | សិស្សពីរនាក់ ឬច្រើនជាងនេះ។ ពួកគេណែនាំមិត្តថ្មី។ | ភាពគួរសម សកម្មភាព/ការងារ ចំណូលចិត្ត អាយុ/កម្រិត | អាស្រ័យលើមេរៀនជាក់ស្តែងសិស្សអាចដើរតួនាទីផ្ទាល់ខ្លួន ឬដើរតួជាតួអង្គប្រតិដ្ឋ។ |
| សូមផ្តល់ឱ្យខ្ញុំ ... | សិស្សគ្រាន់តែសុំឱ្យមិត្តរួមថ្នាក់របស់ពួកគេផ្តល់វត្ថុមួយចំនួននៅជុំវិញខ្លួន។ ជាការពិតណាស់ពួកគេពិតជាត្រូវចាត់ចែងលើវត្ថុទាំងនោះ។ការធ្វើបែបនេះនឹងផ្សារភ្ជាប់ពាក្យជាមួយវត្ថុពិតនៅក្នុងចិត្តរបស់ពួកគេ។ | សម្ភារៈសិក្សា ភាពគួរសម | ទោះបីជាវាគ្រាន់តែជាការសន្ទនាក៏ដោយ ប្រធានបទនេះអាចឱ្យសិស្សស្គាល់ពីការសម្តែងជាតួអង្គ។វាក៏ជាវិធីងាយស្រួលក្នុងការអនុវត្តពាក្យដែលពួកគេនឹងប្រើជារៀងរាល់ថ្ងៃ។បន្ទាប់ពីមេរៀននោះ គ្រូគួរតែអាចបង្រៀនមេរៀនជាភាសាអង់គ្លេសដែលជួយសម្រួលដល់ការបំផុសទឹកចិត្តដល់សិស្ស។ |
| តើ... របស់ខ្ញុំនៅឯណា? | សិស្សម្នាក់កំពុងស្វែងរកសម្ភារៈសិក្សារបស់ខ្លួន ហើយកំពុងសួរមិត្តរួមថ្នាក់របស់គាត់។ | សម្ភារៈសិក្សា ទីតាំង | វាជាសកម្មភាពដែលសាមញ្ញ ដែលគួរតែធ្វើនៅដើមវគ្គសិក្សាភាសាអង់គ្លេស។ សកម្មភាពនេះបម្រើគោលបំណងជាក់ស្តែង។ ប្រសិនបើចង់ធ្វើបានល្អ គ្រូអាច |

| | | | |
|---|---|---|---|
| | | | បង្រៀនជាភាសាអង់គ្លេសមិនមែនភាសាកំណើតទេ។ |
| នៅផ្សារ | អ្នកទិញនិងអ្នកលក់។ តួសម្តែងអាចត្រូវបានផ្តល់លុយក្លែងក្លាយស្លាកតម្លៃ ឬ រូបភាពដើម្បីជួយសម្រួលក្នុងការសម្តែង. | វត្ថុច្រើនប្រភេទផ្សេងៗគ្នាលេខ ទម្ងន់និងការវាស់វែង ភាពគួរសម។ | តួអង្គសម្តែងជាអ្នកលក់-អ្នកទិញគឺជាអ្នកអនុវត្តជាក់ស្តែងហើយសមាសភាពដៃគូអាចប្រើបានគ្រប់កម្រិត។ វាអាចជាការសម្របខ្លួនពីព្រោះអ្នកអាចជ្រើសរើសទីតាំងហាងណាមួយដែលអ្នកចង់បាន។ នៅកម្រិតមូលដ្ឋានសិស្សនឹងទិញផ្លែឈើឬបន្លែហើយអនុវត្តលេខនិងទម្ងន់។ នៅកម្រិតខ្ពស់ពួកគេនឹងសុំចុះថ្លៃនិងតវ៉ាអំពីគុណភាពនៃផលិតផល។ ពួកគេក៏នឹងពណ៌នាអំពីលក្ខណៈបច្ចេកទេសនិងអមដោយការចរចាពីរឿងការសុំបញ្ចុះតម្លៃទំនិញ។ |
| តើលោកអាចជួយខ្ញុំខ្លះៗបានទេអំពីទិសដៅ? | អ្នកទេសចរសួរអ្នកស្រុកអំពីទិសដៅក្នុងទីក្រុង។ | ទីតាំង អាគារ | តួអង្គសម្តែង និងទស្សនិកជនអាចផ្តល់ផែនទីទីក្រុងដូចគ្នា។ទស្សនិកជននឹងពិនិត្យមើលភាពត្រឹមត្រូវនៃទិសដៅនៅលើផែនទី។ ភាពស្មុគស្មាញនៃផែនទីគួរតែ |

| | | | |
|---|---|---|---|
| | | | ផ្ទះបញ្ជាំងពីកម្រិតរបស់សិស្ស។ ទីតាំងមានចំនួន៥ឬ៦គឺគ្រប់គ្រាន់សម្រាប់អ្នកកម្រិតដំបូង។ សិស្សកម្រិតខ្ពស់អាចត្រូវបានផ្តល់ជូនជាមួយនឹងផែនទី ទីក្រុងពិតប្រាកដ។ នៅកម្រិតកាន់តែខ្ពស់ទៅៗ នោះតួអង្គជាអ្នកទេសចរអាចសួរសំណួរអំពីកន្លែងគួរឱ្យចាប់អារម្មណ៍បំផុតនៅក្នុងទីក្រុង។ តួអង្គដៃគូសន្ទនារបស់គាត់អាចលើកឡើងជាសំណើពាណិជ្ជកម្មដូចជា៖ "បងប្អូនជីដូនមួយរបស់ខ្ញុំមានសណ្ឋាគារស្អាតណាស់..." |
| នៅសណ្ឋាគារ | ការកក់បន្ទប់ | គ្រឿងសង្ហារិម<br>បំណងប្រាថ្នា<br>ភាពគួរសម<br>តម្លៃ<br>កាលបរិច្ឆេទ | សេណារីយ៉ូនេះផ្តល់ជាក់ស្តែង ហើយអាចធ្វើឱ្យសិស្សជាច្រើនចាប់អារម្មណ៍ មិនថាសម្រាប់ការងារ ឬជាអ្នកទេសចរនាពេលអនាគត។នៅកម្រិតខ្ពស់ តួអង្គសម្តែងអាចពិភាក្សាអំពីកន្លែងទេសចរណ៍ ឬអំពីអាជីវកម្ម។ |

| | | | |
|---|---|---|---|
| នៅភោជនីយដ្ឋាន | ការកម្មង់អាហារ។ មុខម្ហូបខ្លះ មិនមានទេ។ | មុខម្ហូប<br>លេខ<br>តម្លៃ | សេណារីយ៉ូនេះមានភាពសាមញ្ញណាស់។ សម្រាប់អ្នកកម្រិតដំបូង គ្រូអាចផ្ដល់ជាបញ្ជីមុខម្ហូបដើម្បីជួយសម្រួលក្នុងការសម្ដែង។ សិស្សកម្រិតខ្ពស់ប្រើការស្រមើស្រមៃរបស់ខ្លួន នៅកម្រិតខ្ពស់ជាងនេះ ពួកគេអាចពិភាក្សាអំពីគុណភាពនៃអាហារ ឬ និយាយអំពីអ្វីដែលកំពុងកើតឡើងនៅក្នុងទីក្រុង |
| ការ រៀបចំពិធីជប់លៀង | ពួកគេរៀបចំពិធីខួបកំណើត។ | អាហារ<br>អំណោយ ឬកាដូ<br>សកម្មភាព<br>អនាគត<br>តម្រូវការ | នៅកម្រិតមូលដ្ឋាន វាដូចជាបញ្ជីត្រួតពិនិត្យនៃរបស់របរដែលយើងត្រូវរៀបចំសម្រាប់ពិធីជប់លៀង។ទស្សនិកជនអាចត្រូវបានស្នើឱ្យពិនិត្យមើល ថាតើមានអ្វីសំខាន់ដែលបានបាត់។ នៅកម្រិតខ្ពស់ ជាងនេះ តួអង្គសម្ដែងអាចជជែកតវ៉ាក្នុងកម្មវិធី លើកជាសំណើរសកម្មភាពតាមជម្រើសចែករំលែកយោបល់របស់ខ្លួនលើអ្នកចូលរួម និងអ្វីផ្សេងៗបន្ថែមទៀត។ |
| ខ្ញុំនឹងជូនដំណើរអ្នក! | គាត់កំពុងទូរស័ព្ទទៅម្ដាយមីង | កាលបរិច្ឆេទ<br>ពេលវេលា | វាអាចត្រូវបានធ្វើក្នុង |

| | | | |
|---|---|---|---|
| | របស់គាត់ ដើម្បីរៀបចំផែនការវិស្សមកាលពេលខាងមុខ។ | អនាគត និយាយតាមទូរស័ព្ទ | កម្រិតសាមញ្ញបំផុត ព្រោះគ្រាន់តែចែករំលែកព័ត៌មានជាក់ស្តែង។ជាការពិតណាស់ សិស្សកម្រិតខ្ពស់អាចនិយាយបន្ថែមគម្រោងជាក់លាក់ និងការចងចាំអ្វីដែលខ្លួនបានរៀន។ |
| ការអញ្ជើញ | កាអញ្ជើញមិត្តភក្តិមកពិធីជប់លៀង | កាលបរិច្ឆេទ ពេលវេលា ទីតាំង | នៅកម្រិតមូលដ្ឋាន សេណារីយ៉ូនេះគឺ និយាពីព័ត៌មានសំខាន់ៗដែលអ្នកត្រូវផ្តល់នៅក្នុងការអញ្ជើញ។ជាការពិតណាស់នៅកម្រិតខ្ពស់ អ្នកអាចរួមបញ្ចូលវាក្យសព្ទផ្លូវការនិងការណែនាំផ្សេងៗសម្រាប់ពិធីជប់លៀង។ |
| នៅមន្ទីរពេទ្យ | គាត់បានធ្វើឱ្យបាក់ដៃមិត្តរួមថ្នាក់ម្នាក់របស់គាត់ អំឡុងពេលលេងហ្គេម ។ គាត់ទៅសួរសុខទុក្ខមិត្តរួមថ្នាក់នោះនៅក្នុងមន្ទីរពេទ្យ។ | ផ្នែករាងកាយ សុខភាព បំណងប្រាថ្នា ការសុំទោស ការប្រើកាលអតីតកាល | យើងអាចណែនាំតួអង្គសម្តែងឱ្យបង្ហាញផ្នែករាងកាយនៅពេលពួកគេដាក់ឈ្មោះរាងកាយដែលបង្ហាញនោះ។ |
| រ៉ូបថ្មីរបស់ខ្ញុំ | នាងកំពុងរៀបចំសម្រាប់ពិធីជប់លៀង។ ប៉ុន្តែនាងស្ទាក់ស្ទើរចំ | សំលៀកបំពាក់ ពណ៌ | នៅកម្រិតខ្ពស់ជាងនេះ អ្នកសម្តែងអាចបញ្ចូលការនិយាយដើមគេគ្រប់រូបភាព។ |

| | | | |
|---|---|---|---|
| | ពោះសម្លៀកបំពាក់ដែលគួរពាក់។ | | |
| ការជ្រើសរើសហ្គេម | ក្មេងពីរនាក់ជ្រើសរើសល្បែងមួយដែលពួកគេទាំងពីរមិនយល់ស្របគ្នា។ | ហ្គេម<br>កីឡា<br>សកម្មភាព<br>ចំណូលចិត្ត<br>ប្រៀបធៀប | ប្រសិនបើសាលាមានធនធាន ហ្គេម និងប្រដាប់ប្រដាក្មេងលេងសម្បូរបែបអាចទុកនៅកន្លែងទុកឥវ៉ាន់ចោលរបស់សិស្សដើម្បីសម្រួលដល់ការពិភាក្សា។ |
| ការសុំច្បាប់សម្រាក | គាត់ត្រូវតែចេញដំណើរឱ្យបានលឿនជាងការរំពឹងទុក។ គាត់នឹងឈប់សម្រាក | ភាពគួរសម<br>ភារកិច្ច (ខ្ញុំត្រូវតែ)<br>សកម្មភាពផ្សេងៗ | សេណារីយ៉ូដូចនេះគឺជាការអនុវត្តជាក់ស្តែង។ ភាពគួរសម និងបទដ្ឋានសង្គមក៏ជាវិមាត្រសំខាន់នៃការបង្រៀនភាសាបរទេសផងដែរ។ សូមប្រុងប្រយ័ត្នថា បទដ្ឋានទាំងនោះមានភាព ខុសប្លែកគ្នារវាងប្រទេសដែលនិយាយភាសាអង់គ្លេសទាំងអស់។ |
| ...ខ្ញុំមិនមាន ... | គាត់មានការងារត្រូវធ្វើ ប៉ុន្តែគាត់មិនមានសម្ភារៈដែលត្រូវការ។ | វត្ថុប្រើប្រាស់,<br>គ្រឿងផ្គត់ផ្គង់ | ការប្រែប្រួលជាច្រើនអាចធ្វើទៅបាន អាស្រ័យលើការងារដែលមាននៅនឹងដៃ។<br>វិធីងាយៗដើម្បីអនុវត្តលើវាក្យសព្ទ។ |
| តើមានអ្វីចាក់បញ្ចាំងនៅលើកញ្ចក់ទូរទស្សន៍? | ពួកគេពិភាក្សាគ្នាដើម្បីជ្រើសរើសកម្មវិធីទូរទស្សន៍។ | ប្រភេទ/ការយល់ស្រប/មិនយល់ស្រប<br>ចំណូលចិត្ត | សេណារីយ៉ូល្អគួរតែមានភាពសាមញ្ញ, តែឆ្លើយតបចំពោះគោលបំណង |

| | | | |
|---|---|---|---|
| | | | នៃមេរៀន។ នៅផ្នែកងាយស្រួលអនុវត្តអ្នកអាចផ្តល់ឱ្យសិស្សនូវកម្មវិធីទូរទស្សន៍មួយដើម្បីជួយសម្រួល ហើយគ្រាន់តែធ្វើឱ្យពួកគេរៀនជជែក គ្នាពីពេលវេលា ការចូលចិត្តនិងមិនចូលចិត្ត។ នៅផ្នែកអនុវត្តដែលស្មុគស្មាញ សិស្សអាចបញ្ចេញមតិរិះគន់ស៊ីជម្រៅពីកម្មវិធីទូរទស្សន៍។ |
| ផ្ទះថ្មីរបស់ខ្ញុំ | កូនក្រមុំអញ្ជើញមិត្តភក្តិមួយចំនួនទៅលេងផ្ទះថ្មីរបស់នាង | បន្ទប់<br>គ្រឿងសង្ហារិម<br>ទីតាំង<br>ពណ៌ | ជម្រើសមួយទៀតនោះគឺភ្នាក់ងារអចលនទ្រព្យ សេណារីយ៉ូនេះអាចត្រូវបានធ្វើឡើងតាមកម្រិតផ្សេងៗគ្នា។ វាក្យសព្ទនឹងមានតិចឬច្រើនដែលត្រូវយកមកប្រើ។ រីឯរូបភាពឬគម្រោងផ្ទះអាចត្រូវបានផ្តល់ជូន ដើម្បីជំរុញឱ្យមានការពិភាក្សា |

# កម្រិតមធ្យម

| ប្រធានបទ/ ជំនាញទំនាក់ទំនង | ការពិពណ៌នា | លទ្ធផលភាសាវិទ្យា (វេយ្យាករណ៍/ វាក្យសព្ទ) | កំណត់ចំណាំ |
|---|---|---|---|
| សូមចំណាំថាសេណារីយ៉ូភាគច្រើននៅកម្រិតមូលដ្ឋានក៏អាចសម្តែងបាននៅកម្រិតមធ្យម ដែរប្រសិនបើមានការណែនាំសមស្រប។ | | | |
| ឪពុកម្តាយនិងគ្រូបង្រៀន | ឪពុកម្តាយត្រូវបានកោះអញ្ជើញទៅចូលរួមប្រជុំជាមួយលោកគ្រូអ្នកគ្រូដើម្បីជជែកអំពីបញ្ហាមួយចំនួន។ | ជីវិតសាលារៀន<br>ឥរិយាបថ<br>ការសុំទោស<br>កាតព្វកិច្ច និងដំបូន្មាន (ត្រូវតែ គួរតែ)<br>អតីតកាល និងអនាគតកាល | សេណារីយ៉ូនេះអាចផ្តល់ភាពរីករាយច្រើន ព្រោះសិស្សអាច កំណត់បានស្ថានភាពជាក់លាក់ផ្សេងៗ។<br>វាផងដែរក៏ជាឱកាសមួយដើម្បីពិពណ៌នាពីគ្រូរបស់ពួកគេខ្លះៗដែរ<br>ទោះជាយ៉ាងណាក៏<br>ដោយត្រូវប្រាកដថាសម្លេងនិយាយនៅតែត្រឹមត្រូវនិងហាមការបៀតបៀនគ្រប់ប្រភេទ។<br>ក្នុងស្ថានភាពមានមន្ទិល វាជាការល្អប្រសើរជាងមុនដើម្បីផ្អែកលើសេណារីយ៉ូប្រតិដ្ឋណាមួយ។ |

| | | | |
|---|---|---|---|
| ចុះវិស្សមកាលរបស់អ្នកវិញ ? | មិត្តភក្តិជជែកគ្នាអំពីវិស្សមកាលរបស់ខ្លួន។ | អតីតកាល<br>ទីតាំង<br>ការកម្សាន្ត<br>ប្រវត្តិសាស្ត្រ | សិស្សអាចផ្សារភ្ជាប់ប្រធានបទនេះបានយ៉ាងងាយ។ ទោះជាយ៉ាងណាក៏ដោយពួកគេមួយចំនួន<br>អាចមិនមានអារម្មណ៍ល្អក្នុងការនិយាយ<br>ពីបទពិសោធផ្ទាល់ខ្លួនដោយសារហេតុផលមួយចំនួន។ ចូរប្រាប់ ពួកគេថាអាចចែករំលែកអំពីវិស្សមកាលប្រតិដ្ឋរបស់ខ្លួនបាន។ វាមិនសំខាន់ទេថាតើវាជាការពិតឬប្រតិដ្ឋ។<br>សេណារីយ៉ូផ្សេងៗពីនេះអាចត្រូវបានស្នើឡើងបានយ៉ាងងាយដោយបំផុសទីតាំង (វិស្សមកាលវប្បធម៌ ប្រទេស ធ្វេរជាដើម)។ |
| ការណាត់ជួប | ពួកគេមានការណាត់ជួប។ នាងមកយឺត។ | ការសុំទោស<br>អតីតកាល<br>សកម្មភាព<br>វាក្យសព្ទស្នេហា | ជាការពិតណាស់ អ្នកអាចផ្លាស់ប្តូរតួនាទីតួប្រុស និងតួស្រី។ សេណារីយ៉ូនេះពិតជាបង្កភាពសប្បាយរីករាយប្រសិនបើតួសម្តែងមានទំនុកចិត្ត |

| | | | |
|---|---|---|---|
| | | | គ្រប់គ្រាន់។ វាកាន់តែប្រសើរ ប្រសិនបើមានអ្នកស្ម័គ្រចិត្ត ចូល<br><br>សម្តែង។ |
| បំណុល | គាត់មិនមានលុយ ទេ។ គាត់សុំ ពន្យារពេល។ | ការសុំទោស<br><br>ការជជែកវិភាគ<br><br>លុយ<br><br>លេខ<br><br>ការងារ | តាមទស្សនៈភាសាវិទ្យា សេណារីយ៉ូនេះមិនពិបាកស ម្តែងទេ ប៉ុន្តែស្ថានភាពតម្រូវឱ្យសិស្ស ចេះជជែកតវ៉ា។ |
| បង្អួចខូច | គាត់បានធ្វើឱ្យ បង្អួចបែកពេល លេង<br><br>បាល់ទាត់។ | ការសុំទោស<br><br>អារម្មណ៍ | ឧប្បត្តិហេតុផ្តល់នូវចំណុច ចាប់ផ្តើមដ៏ល្អសម្រាប់រឿងមួ យ។ |
| គ្រោះថ្នាក់ | អ្នកបើកបរពីរនាក់ បានឈ្លោះគ្នា ក្រោយគ្រោះថ្នាក់ កើតឡើង។ | វិថី<br><br>យានជំនិះ<br><br>ច្បាប់ចរាចរណ៍ | ជាការប្រសើរប្រសិនបើសិ ស្សមានចំណេះដឹងខ្លះៗអំពី ច្បាប់ចរាចរណ៍។ ផែនទីនៃទី តាំង គ្រោះថ្នាក់អាចត្រូវបានផ្តល់ ជូនដើម្បីជំរុញការពិភាក្សា។ |
| ការយឺតយ៉ាវ | យុវជនម្នាក់ ត្រឡប់មកផ្ទះវិញ ទាំងកណ្តាល អធ្រាត្រ។ | ការសុំទោស<br><br>ការជជែកវិភាគ<br><br>ពេលវេលា | សិស្សដែលមានកេរ្តិ៍ឈ្មោះ មិនល្អនឹងចូលចិត្តសម្តែង តួនាទីជាអ្នកកាន់អំណាច ហើយមួយចំនួនក្នុង ចំណោមពួកគេអាចសម្តែង |

| | | | |
|---|---|---|---|
| | ឪពុកម្ដាយខឹងសម្បាជាខ្លាំង។ | សកម្មភាព<br>គ្រួសារ<br>មិត្តភក្តិ | បានយ៉ាងល្អ ។<br>It is good to break their usual image, and to give "bad guys" an opportunity to be on the good side.<br>វាជារឿងល្អកាលដែលផ្លាស់ប្ដូររូបភាពធម្មតារបស់ពួកគេ ហើយផ្ដល់ឱកាសឱ្យ "មនុស្សអាក្រក់" ដើម្បីក្លាយជាមនុស្សល្អ។ (ពិនិត្យឃ្លានេះឡើងវិញ) |
| ការលេងល្បែងដោយយុត្តិធម៌ | សិស្សម្នាក់បានឈ្នះលើការប្រកួត។ មិត្តរួមថ្នាក់របស់គាត់ធ្វើពុតថាគាត់បានបន្លំ។ | ភាពគួរសម<br>យល់ស្រប<br>មិនយល់ស្រប!<br>ស្នើសុំការពន្យល់<br>កីឡា | ឆ្លើយតបដោយមានសុជីវធម៌ ដើម្បីបង្ហាញពីការមិនយល់ស្រប។<br>គ្រូគួរលើកទឹកចិត្តសិស្សឱ្យចេះគួរសម។ សេណារីយ៉ូនេះមិនសំដៅចំពោះការរៀនពីពាក្យស្លោកទេ (ដែលក្មេងជំទង់រៀនបានយ៉ាងល្អដោយខ្លួនឯងដោយមិនចាំបាច់មានគ្រូបង្ហាញ)។ |
| តើថ្លៃប៉ុន្មាន? | គាត់បានចំណាយប្រាក់ខែទាំងអស់របស់គាត់។ មិនមានលុយនៅ | លុយ<br>លេខ | វាមានលក្ខណៈស្រដៀងទៅនឹង |

| | | | |
|---|---|---|---|
| | សល់ទេ។ ប្រពន្ធគាត់ខឹងសុំការពន្យល់។ | | សេណារីយ៉ូជាមួយអ្នកលក់ ប៉ុន្តែប្រសិនបើ មានការកែប្រែបន្តិចបន្តួចនោះនឹងស្តារចំណាប់អារម្មណ៍របស់សិស្សដែលមានកម្រិតខ្ពស់ជាងមុន។ |
| សិស្សល្អមិនចេះឈ្លោះគ្នា! | សិស្សពីរបីនាក់បានចូលរួមក្នុងការវាយតប់។ នាយកសាលាស្នើសុំការពន្យល់ពីពួកគេ។ | ច្បាប់<br><br>អតីតកាល<br><br>ធ្វើ និងមិនត្រូវ<br><br>ការពិតនិងកុហក | សេណារីយ៉ូនេះអាចមានភាព ងាយស្រួល ជាមួយតួអង្គសម្តែង៣នាក់ សិស្ស ២ នាក់ និងនាយកសាលា១។ ទស្សនៈផ្ទុយគ្នារបស់សិស្សផ្តល់នូវវិធីដ៏ល្អមួយដើម្បីពង្រឹងការពិភាក្សា។ ប្រាកដណាស់ សេណារីយ៉ូនេះ<br><br>ផ្តល់ការអប់រំស៊ីជម្រៅ ប្រសិនបើ "សិស្ស" ប្រើទស្សនៈផ្ទុយលើអង្គហេតុមួយ (ពាក្យអសុរស) ដើម្បីការពារ ឬប្រឈមនឹងគ្នា ប៉ុន្តែ "នាយក" ជាបុគ្គលដែលអាចរក្សាការ<br><br>ពិភាក្សាប្រកបដោយសុជីវធម៌។ដោយចៃដន្យ សេណារីយ៉ូនេះអាចល្អ |

| | | | |
|---|---|---|---|
| | | | សម្រាប់សិស្សដែលមាន ប្រវត្តិកំណត់ត្រាមិនល្អ។ ពួកគេពេញចិត្តដើរតួ ជាអ្នកនាយកសាលា។ សូម ប្រាប់សិស្សថា រឿងមានលក្ខណៈប្រតិដ្ឋទាំងស្រុង។ |
| ការប្រមាថ | សិស្សពីរនាក់ខឹងគ្នា ទៅវិញទៅមក ។ អ្នកទីបីព្យាយាមផ្សះផ្សារពួកគេ។ | ពាក្យសម្ដីប្រយោល អតីតកាល អារម្មណ៍ | ត្រូវប្រាកដថាការ ប្រើសម្លេងនៅតែត្រឹមត្រូវ។ វាគួរតែនៅជាសេណារីយ៉ូប្រតិដ្ឋ។ |
| បុរសដែលមាន ឥរិយាបថឆ្កាំឆ្គង | គាត់កំពុងលើកជាសំណើ។ នាងបដិសេធ។ | ភាពគួរសម ជំនាញសង្គម សកម្មភាព ស្នេហា | នេះជាសេណារីយ៉ូដែល ផ្តល់ទាំងភាពរីករាយ និងភាពជាក់ស្តែងផងដែរ។ តើធ្វើដូចម្តេចដើម្បីលុបបំបាត់មនុស្សដែល ជ្រាតជ្រែកឬរំខានដោយមិនបង្ហាញភាពច្រឡើសបើស ? |
| ឆ្នោត | គាត់បានឈ្នះឆ្នោត ចំនួនពីរលានរៀល។ មិត្តភក្តិរបស់គាត់ឱ្យយោបល់ពីរបៀបចាយលុយទាំងនោះ។ | ក្តីសុបិន្ត បំណងប្រាថ្នា វត្ថុ សកម្មភាព | ចូរកត់ចំណាំថា យើងមិនចង់លើកទឹកចិត្តមនុស្សឱ្យលេង ឆ្នោតនោះទេ។ |

| | | | |
|---|---|---|---|
| ការហៅជាងទឹក | ជាងទឹកត្រូវបានសន្ទត់ថាមក ប៉ុន្តែបែរជាមិនមក។ អតិថិជនមានអារម្មណ៍ខឹងសម្បា។ | ភាពគួរសម<br>ពេលវេលា<br>កាតព្វកិច្ច | តាមរយៈការហៅទូរស័ព្ទ។ |
| ការរៀបចំពិធីមង្គលការ | ម្ដាយរបស់កូនក្រមុំផ្ដល់ការណែនាំដល់អ្នករៀបចំកម្មវិធី។ | កាតព្វកិច្ច<br>ត្រូវតែ | តួនាទីយេនឌ័រផ្សេងទៀតអាចធ្វើទៅបាន។ភ្ញៀវកម្មវិធីអាចត្រូវបានស្នើសុំធ្វើការពិនិត្យ ថាតើ ការណែនាំ<br>នេះមានប្រយោជន៍ដែរឬទេ។ វិធាននេះនឹងធ្វើឱ្យពួកគេយកចិត្តទុកដាក់ចំពោះការពិភាក្សា |
| ឧបទ្ទវហេតុមួយកើតឡើង | មានឧបទ្ទវហេតុមួយកើតឡើង។ អ្នកជួយសង្គ្រោះកំពុងសាកសួរជនរងគ្រោះ។ | ផ្នែករាងកាយ<br>ការឈឺចាប់<br>សុវត្ថិភាព | វាអាចត្រូវបានផ្សារភ្ជាប់ជាមួយនឹងកិច្ចការគម្រោងស្ដីពីការបង្គ្រោះបឋម។ |
| អ្នកប្រដាល់ | គ្រូបង្វឹកផ្ដល់អនុសាសន៍ដល់អ្នកប្រដាល់។ | គួរ<br>ចាំបាច់ | សេណារីយ៉ូនៃការបង្វឹកនេះអាចកែសម្រួលបានយ៉ាងងាយ<br>ដើម្បីផ្សារភ្ជាប់នឹងការផ្ដោតអារម្មណ៍របស់<br>សិស្ស។ |

| | | | |
|---|---|---|---|
| ប៊ុប (Bob) កំពុងវង្វេងផ្លូវ | ម្ដាយកំពុងស្វែងរកកូនប្រុសខ្លួនដែលមិនបានត្រឡប់មកផ្ទះដើម្បីញ៉ាំអាហារពេលល្ងាច។ គាត់មានការព្រួយបារម្ភយ៉ាងខ្លាំង។ | ការពិពណ៌នារូបរាង<br>សំលៀកបំពាក់<br>ពណ៌ | សេណារីយ៉ូនេះអាចអនុវត្តបានចំពោះមនុស្សគ្រប់ប្រភេទ។ វាមិនចាំបាច់ជាមួយតែម្ដាយនិងកូនប្រុសរបស់គាត់នោះទេ។ |
| ពស់! | មានពស់មួយក្បាល។ នាងមានការភ័យខ្លាចខ្លាច។ គាត់ល្បួងលោមនាង។ | អារម្មណ៍<br>គ្រោះថ្នាក់<br>ការចាក់ថ្នាំ | ជាការពិតណាស់ យើងអាចដាក់ផ្លាស់ប្ដូរតួប្រុសស្រីឆ្លាស់គ្នា។ |
| ឈឺ | គាត់មានជម្ងឺ។ គាត់មានជម្ងឺគ្រុនក្ដៅ។ ម្ដាយរបស់គាត់មានការព្រួយបារម្ភ។ | សុខភាព<br>ផ្នែករាងកាយ<br>សាលារៀន<br>អនុសាសន៍<br>"អ្នកគួរតែ"<br>"ធ្វើ និងមិនធ្វើ" | តួសម្ដែងត្រូវបានលើកទឹកចិត្តឱ្យដើរតួនាទីផ្សេងៗគ្នាដូចជា សម្ដែងធ្វើជាស្រែកថ្ងូរដោយការឈឺចាប់ ស្រែកយំជាដើម។ល។ ការភ្ជាប់កាយវិការនិងកិរិយាបថពេលអនុវត្តភាសានឹងធានាបានចំពោះការទន្ទេញវាក្យសព្ទកាន់តែប្រសើរ។ |
| អវត្តមាន | ថៅកែស្រីបានហៅបុគ្គលិកដែលអវត្តមានមក | សុំទោស<br>សកម្មភាព<br>បញ្ហា | សេណារីយ៉ូនេះមានគោលបំណងជាក់ស្ដែង។ លើសពីលេសមិនធម្មតាដែលសិស្សអាចបង្កើតបាន |

| | | | |
|---|---|---|---|
| | ផ្ដល់ការពន្យល់ពីមូលហេតុ។ | | ជាការសំខាន់នោះគឺបញ្ជាក់នូវវិធីដោះស្រាយដែលមានសុជីវធម៌ពេលផ្ដល់ការសុំទោស។ |



## កម្រិតខ្ពស់

| ប្រធានបទ/ ជំនាញទំនាក់ទំនង | ការពិពណ៌នា | លទ្ធផលភាសាវិទ្យា (វេយ្យាករណ៍/ វាក្យសព្ទ) | កំណត់ចំណាំ |
|---|---|---|---|
| សូមចំណាំថា សេណារីយ៉ូភាគច្រើននៅកម្រិតមូលដ្ឋាន និងមធ្យមក៏អាចយកមកសម្តែងនៅកម្រិតខ្ពស់ផងដែរ ដោយមានការណែនាំបានត្រឹមត្រូវ។ | | | |
| សម្ភាសន៍ការងារ | ប្រធានគ្រប់គ្រងធនធានមនុស្សកំពុងសាកសួរបេក្ខជន។ | វាក្យសព្ទវិជ្ជាជីវៈ<br>ភាពគួរសម | ការប្រែប្រួលជាច្រើនអាចត្រូវបានស្នើឡើងអាស្រ័យលើការងារដែលបានជ្រើសរើស។ វាអាចជាស្ថានភាពជាក់ស្តែងក្នុងការហាត់សមប្រសិនបើសិស្សមានអាយុគ្រប់គ្រាន់ហើយប្រសិនបើគ្រូបង្រៀនយល់ដឹងពីវិស័យធនធានធនធានមនុស្ស។ |
| ព័ត៌មានទូរទស្សន៍ | វាគ្មិន កំពុងប្រកាសព័ត៌មាន។ | អាស្រ័យលើប្រធានបទនៅជាក់ស្តែង។ | ទាមទារឱ្យមានការរៀបចំខ្លះៗ។ ដើម្បីត្រូវបានសម្តែងឱ្យបានច្រើនតាមដែលអាចធ្វើទៅបានដូចជាកម្មវិធីទូរទស្សន៍ពិត។ |

| | | | |
|---|---|---|---|
| | | | វាអាចមានតួអង្គជាច្រើន ប្រសិនបើអ្នកនិយាយអញ្ជើញអ្នកយកព័ត៌មានឱ្យសម្ភាសនរណាម្នាក់។ |
| ការនិយាយដើម | នាយកសាលានឹងរៀបការ។ សិស្សបញ្ចេញមតិ | ខ្ញុំគិតថា<br>ខ្ញុំជឿជាក់ | .ការនិយាយដើមគេអាចផ្តល់នូវសេណារីយ៉ូគ្រប់ប្រភេទសម្រាប់ការសម្តែង។ ប៉ុន្តែត្រូវប្រាកដថា<br>សម្លេងនៅតែត្រឹមត្រូវ និងគួរជៀសវាង<br>ប្រសិនបើមានបរិយាកាសមិនល្អក្នុងថ្នាក់រៀន។ |
| ការកាត់ទោស | បុរសម្នាក់ត្រូវបានគេចោទប្រកាន់ពីបទ សម្លាប់ប្រពន្ធខ្លួន។ | យុត្តិធម៌<br>ឧក្រិដ្ឋកម្ម<br>សកម្មភាព<br>អតីតកាល<br>សម្មតិកម្ម | សេណារីយ៉ូនេះត្រូវបានធ្វើយ៉ាងល្អដោយប្រើកម្មវិធី ខេនវីស (Canvas) ( ឧ.ការកំណត់ឈុតឆាកសម្តែង )។ ព្យាយាមកំណត់តួនាទីតួអង្គនៃសាលាក្តីពិត (មានជាមេធាវី ចៅក្រម គណៈវិនិច្ឆ័យ សាក្សី |

| | | | |
|---|---|---|---|
| | | | អ្នកជំនាញ)។ អ្វីគ្រប់យ៉ាងមិនចាំបាច់សរសេរជាលាយលក្ខណ៍អក្សរនោះទេ។ ចំពោះសិស្សកម្រិតខ្ពស់ ការសម្តែងរឿងនេះអាចផ្តល់ភាពសប្បាយរីករាយ និងគួរឱ្យចាប់អារម្មណ៍ក្នុងការបង្កើតឧប្បត្តិហេតុមួយចំនួន និងមើលឃើញពីរបៀបដែលសិស្សអាចសម្របខ្លួនទៅនឹងស្ថានភាពថ្មី។ ជាឧទាហរណ៍ ប្រាប់សាក្សីម្នាក់ឱ្យផ្លាស់ប្តូរសក្ខីកម្មរបស់ខ្លួនពេលសម្តែង។ |
| សុន្ទរកថា | គាត់បានទទួលមរណៈភាពហើយ។ មិត្តភក្តិរបស់គាត់កំពុងនិយាយអំពីគាត់។ | អតីតកាល<br>អារម្មណ៍<br>សកម្មភាព<br>អាកប្បកិរិយា | វាក៏អាចត្រូវបានធ្វើឡើងជាសុន្ទរកថាជាជាងការសន្ទនា។ ក្នុងករណីនេះ ត្រូវធ្វើតាមការកំណត់នៃលក្ខខណ្ឌ ហើយអនុវត្តបច្ចេកទេស |

| | | | |
|---|---|---|---|
| | | | វោហាសាស្ត្រដែល សមស្រប។ |
| ស្នេហា | គាត់មានស្នេហា ប៉ុន្តែអៀនប្រៀនប ន្តិច។ មិត្តម្នាក់ បាន ផ្តល់ដំបូន្មានខ្លះៗ | អារម្មណ៍<br>សកម្មភាព<br>ដំបូន្មាន | ប្រាប់សិស្សថា អាកប្ប កិរិយាក្នុងការសម្តែង ជាការប្រតិដ្ឋ ដើម្បីជៀសវាងភាព អាម៉ាស់ផ្សេងៗ។ |
| ការធ្វើដំណើរឥត គម្រោង | គាត់កំពុងរ៉ាយរ៉ាប់ រឿង ពីការធ្វើដំណើរ<br>របស់គាត់។ មិត្តរបស់<br>គាត់មិនជឿរឿង ហ្នឹងទេ។ | អតីតកាល<br>ព្រឹត្តិការណ៍<br>ជំនឿ<br>ចំណេះដឹង វប្បធម៌ | រួមមានការមិនជឿនៃ តួសម្តែងក្នុង សេណារីយ៉ូ បង្ហាញពី ភាពត្រឹមត្រូវនៃការពិ ភាក្សា និងបង្កើត<br>អន្តរកម្មកាន់តែច្រើន |
| ឃាតកម្ម! | ប៉ូលិសកំពុង ស៊ើបអង្កេតករណី ឃាតកម្ម និង សួរចម្លើយ ជនសង្ស័យ។ | អតីតកាល<br>ឧក្រិដ្ឋកម្ម<br>ទំនាក់ទំនង | សេណារីយ៉ូនេះអាច មានតួសម្តែងច្រើន ជាងពីរនាក់។ដើម្បី បង្កើនចំណាប់អារ ម្មណ៍ពីទស្សនិកជន ស្នើឱ្យពួកគេកត់<br>ចំណាំ ហើយពិនិត្យ មើលលើភាពមិនស៊ី<br>សង្វាក់គ្នានៅក្នុង<br>សក្ខីកម្ម។ |

| | | | |
|---|---|---|---|
| និទានរឿងមួយឱ្យខ្ញុំស្តាប់ | ជីតា (ឬជីដូន) និទានរឿងឱ្យចៅៗស្តាប់។ | | ការនិទានរឿងអាចមានលក្ខណៈលម្អៀងបន្តិច។ប៉ុន្តែវាជំរុញឱ្យសិស្សចេះផ្តល់នូវពាក្យពេចន៍សំបូរបែបដោយឡែកសេណារីយ៉ូសម្តែងផ្សេងទៀតត្រូវបានកំណត់ដោយប្រើបានជាប្រយោគខ្លីៗក្នុងការសម្តែងតែប៉ុណ្ណោះ។ |
| | | អតីតកាល<br>ចំណេះដឹងវប្បធម៌ | វាជារឿងសំខាន់ក្នុងការពន្យល់ពីតួនាទីរបស់ពួកគេដែលដើរតួជា "ចៅ" ឬពួកគេអាចត្រូវបានកំណត់មិនឱ្យធ្វើអ្វីទាំងអស់។ តួ"ចៅ" អាចបង្ខំតួ"ជីតា" ឱ្យសម្របសាច់<br>រឿងដោយសួរជាសំណួរ ឬដោយបញ្ចេញមតិដែលមើលទៅដូចជាកូនពិតៗនឹងធ្វើអញ្ចឹងដែរ។ |

# សេណារីយ៉ូផ្ទាល់របស់ខ្ញុំ

សូមកត់ចំណាំសេណារីយ៉ូផ្ទាល់របស់អ្នកដែលមានក្នុងតារាងខាងក្រោម។

| ប្រធានបទ/ជំនាញទំនាក់ទំនង | ការពិពណ៌នា | លទ្ធផលភាសាវិទ្យា (វេយ្យាករណ៍/វាក្យសព្ទ) | កំណត់ចំណាំ |
|---|---|---|---|
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |

## ការឆ្លុះបញ្ចាំងលើម៉ោងបង្រៀនដោយប្រើវិធីសម្ដែងតួ

ទំព័រនេះបង្កើតឡើងដើម្បីជួយឱ្យអ្នកឆ្លុះបញ្ចាំងលើការអនុវត្តរបស់អ្នកផ្ទាល់។ វាបានណែនាំថា អ្នកគួរតែពិភាក្សាអំពីសកម្មភាពនានាភ្លាមៗបន្ទាប់ពីបានកើតឡើង ហើយអ្នកក៏គួរតែរក្សាទុកឯកសាររបស់អ្នកនៅកន្លែងដែលសមស្រប សម្រាប់ជាការប្រើប្រាស់បន្ត។

កាលបរិច្ឆេទ៖

កម្រិត៖

ប្រធានបទ៖

វត្ថុបំណងមេរៀន៖

តើសិស្សមានប្រតិកម្មយ៉ាងណាចំពោះការសម្ដែងតួ? តើពួកគេទាំងអស់គ្នាបានចូលរួមយ៉ាងសកម្មដែរឬទេ? ប្រសិនបើមិនសកម្ម ជាអ្នកណាដែលមានភាពខ្មាសអៀន? តើអាចធ្វើអ្វីខ្លះបានដើម្បីលើកទឹកចិត្តពួកគេឱ្យចូលរួម?

តើសិស្សទាំងអស់បានចែករំលែកពីចំណាប់អារម្មណ៍ដែលអាចឱ្យខ្ញុំយកមកប្រើការក្នុងសកម្មភាពសម្ដែងមួយទៀតដែរឬទេ?

តើមានអ្វីដែលអាចយកមករៀបចំបានប្រសើរជាងមុន?

តើសិស្សបានកត់ចំណាំត្រឹមត្រូវទេបន្ទាប់ពីវគ្គផ្ដល់យោបល់?

វិធីសម្តែងតួ អាចជាសកម្មភាពដ៏ល្អបំផុតសម្រាប់ពង្រឹងជំនាញនិយាយ។ វាពិតជាសកម្មភាពពេញលេញ ដែលអ្នកអាចអនុវត្តបាននៅក្នុងថ្នាក់រៀនធម្មតា។ គោលការណ៍នៃវិធីនេះងាយស្រួលយល់។ សិស្សទទួលបានសេណារីយោនិម្មិតមួយ ហើយធ្វើការសន្ទនាដូចជាពួកគេជាតួអង្គក្នុងសាច់រឿង។ តាមលក្ខណៈធម្មជាតិ ចំពោះសិស្សតូចៗ ពួកគេចូលចិត្តសម្តែង។ ប៉ុន្តែ ដើម្បីធ្វើឱ្យការសម្តែងក្លាយជាបទពិសោធរៀន និងអាចអនុវត្តវាឱ្យមានជាសកម្មភាពដ៏មានប្រសិទ្ធភាពក្នុងថ្នាក់រៀន មានគោលការណ៍មួយចំនួនដែលគ្រូគួរពិចារណា។

លោក ស្តេននីស្លាស កូវ៉ាលស្គី (Stanislas Kowalski) គឺជាគ្រូប្រឹក្សាជាន់ខ្ពស់នៃមជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី (NGPRC) ដែលមានភារកិច្ចពិនិត្យមើលលើផ្នែកកម្មវិធីសិក្សា។ ទន្ទឹមនឹងនោះដែរ គាត់ក៏ជាទីប្រឹក្សាសម្រាប់កម្មវិធីផ្សេងៗរបស់ក្រសួងអប់រំ យុវជន និងកីឡា។ លោកស្តេននីស្លាសធ្លាប់ធ្វើការជាអ្នកអប់រំនៅបណ្តាប្រទេសជាច្រើន និងនៅកម្រិតផ្សេងៗគ្នា។

នៅប្រទេសបារាំង គាត់ធ្លាប់ជាគ្រូបង្រៀនអក្សរសាស្ត្រនៅវិទ្យាល័យ។ ផងដែរនោះ គាត់ក៏ធ្លាប់ជាគ្រូបង្រៀនភាសាបារាំងនៅសាកលវិទ្យាល័យ Central South University ក្នុងទីក្រុង Changsha (ប្រទេសចិន) ហើយធ្លាប់ជានាយកមជ្ឈមណ្ឌលបណ្តុះបណ្តាលអក្ខរកម្មនៅប្រទេស ជីប៊ូទី (Djibouti) នៃអាហ្វ្រិកខាងកើត។

+855 11 607 938
ngprc@nie.edu.kh
facebook.com/ngprc16
www.ngprc.edu.kh